Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

# សៀវភៅ
# មគ្គុទេសក៍

## ដំណោះស្រាយទឹកឆ្លាតវៃ
## និងដំណាំសាកវប្បកម្ម
## ឆ្លាតវៃអាកាសធាតុ



សេចក្ដីណែនាំសម្រាប់កសិករ
ឱ្យវិនិយោគលើបច្ចេកវិជ្ជាទឹកឆ្លាតវៃ
សម្រាប់ដំណាំសាកវប្បកម្ម
ដែលធន់នឹងអាកាសធាតុ

CHAIN

SNV

swisscontact

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

# សៀវភៅ
# មគ្គុទេសក៍

## ដំណោះស្រាយទឹកឆ្លាតវៃ
## និងដំណាំសាកវប្បកម្ម
## ឆ្លាតវៃអាកាសធាតុ

SNV

swisscontact

គម្រោងឈេន

សៀវភៅមគ្គុទេសក៍សម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារកសិកម្ម

# ដំណោះស្រាយទឹកឆ្លាតវៃ និងដំណាំសាកវប្បកម្មឆ្លាតវៃអាកាសធាតុ


ចងក្រងដោយ៖
លោកស្រី ឃឹម គឹមបួយ
លោក រិត អូវើម៉ាស៍
លោក លឹម សុគន្ធដារុណ
លោក លឹម ណាលុច


---


**សូមថ្លែងអំណរគុណចំពោះអ្នកពិនិត្យ និងកែសម្រួល៖**
លោកជំទាវបណ្ឌិត យ៉ើ អាស៊ីគិន
លោកស្រី ម៉ារិត វ៉ាន់ស្ស៊ី
លោក រិត វ៉ាន់ គូលេន
លោក ហែម សុវណ្ណារិទ្ធ
បណ្ឌិត សុខ គឹមឈិន
លោក ឱ ធី
លោក អ៊ុក វណ្ណារ៉ា

**និងសូមថ្លែងអំណរគុណចំពោះអ្នកចូលរួមចំណែក៖**
លោក ស្រី សុខជា លោកស្រី យស មន្នីរ័ត្ន លោក សោម សាល លោក អ៊ុន រើន
មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


---


**រចនា និងរៀបចំបោះពុម្ពផ្សាយ៖** ក្រុមហ៊ុន អឹម អ  អេ ឌីហ្សាញ
**រៀបចំរូបភាព៖** គម្រោងឈេន
**អ្នកពិនិត្យផ្ទៀងផ្ទាត់៖** លោក រ៉ូណាល់ដូ ម៉ុងតេកាល់វ៉ូ
**បកប្រែជាភាសាខ្មែរ៖** លោក ង៉ែត សុភា

**គម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភ (ឈេន) អេសអិនវី កម្ពុជា និងអគ្គនាយកដ្ឋានកសិកម្ម**



អ៊ីមែល៖ horticulturecambodia@gmail.com
វិបសាយ៖ https://web.maff.gov.kh
ហ្វេសប៊ុក៖ @សាកវប្បកម្មកម្ពុជា Horticulture in Cambodia

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

**Swiss Agency for Development and Cooperation SDC**

# បុព្វបទ

វិស័យកសិកម្មនៅប្រទេសកម្ពុជាបានបង្ហាញការបន្តរីកលូតលាស់ទាំងផលិតកម្ម និងការនាំចេញទោះបី ជាមានការរីករាលដាលនៃជំងឺកូវីត១៩។ ទោះបីយ៉ាងណាក៏ដោយ ភាពក្រីក្រនៅតែជាកត្តាចំបងកើតមានឡើងនៅតំបន់ជនបទ ដែលប្រហែលជា ៨០% នៃប្រជាជនក្រីក្រចំនួន ២,៥លាននាក់កំពុងរស់នៅក្នុងតំបន់ជនបទ។ ផលិតភាពទាបនៃកសិករខ្នាតតូចកម្ពុជា បានកើតឡើងដោយការប្រើប្រាស់នៅមានកម្រិតនូវធាតុចូលកសិកម្មដែលមានគុណភាព ការអនុវត្តតាមស្តង់ដាបច្ចេកទេស និងនវានុវត្តន៍ ព្រមទាំងឱកាស និងព័ត៌មានទីផ្សារ។ សម្ពាធនៃធនធានធម្មជាតិ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមបន្ថែមទៀត។ ចំណែកការចូលរួមក៏នៅមានកម្រិតពីសំណាក់វិស័យឯកជន លើសេវាផ្សព្វផ្សាយកសិកម្ម និងកិច្ចសហការខ្សោយជាមួយតួអង្គមកពីវិស័យសាធារណៈ បានរាំងការអភិវឌ្ឍ ភាពរីកចម្រើនរបស់កសិករខ្នាតតូច។ កម្ពុជាពុំទាន់បានផ្គត់ផ្គង់បន្លែក្នុងស្រុកគ្រប់គ្រាន់នៅឡើយ ម៉្យាងវិញទៀត កំណើនសេដ្ឋកិច្ចរហ័សបានបង្ហាញនូវតម្រូវការកាន់តែខ្ពស់សម្រាប់ការបរិភោគបន្លែ និងផ្លែឈើដែលសុវត្ថិភាព និងគុណភាពល្អ។ កត្តានេះជាឱកាសដ៏មានតម្លៃរបស់កសិករខ្នាតតូច និងអ្នកកែច្នៃ ជាពិសេសស្ត្រីក្នុងការបង្កើនប្រាក់ចំណូល និងសន្តិសុខស្បៀង។ ជាងនេះទៅទៀត ភាពប្រសើរឡើងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ បានជំរុញការបំលាស់ទីរបស់ប្រជាជនក្រីក្រជនបទ ដោយផ្តល់ឱ្យពួកគេនូវលទ្ធភាពទទួលបានទីផ្សារចម្រុះ និងឱកាសការងារជាច្រើន។

ឆ្លើយតបទៅនឹងបញ្ហា និងឱកាសទាំងនេះ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) បានអភិវឌ្ឍគម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភ ដែលហៅកាត់ថា (គម្រោងឈេន) ជាកម្មវិធីអភិវឌ្ឍន៍សម្រាប់រយៈពេលប្រាំបីឆ្នាំ (២០១៤ - ២០២២) ដោយសហការជិតស្និទជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងបណ្តាខេត្តគោលដៅ។ គម្រោងឈេនបានប្រើប្រាស់វិធីសាស្ត្រអភិវឌ្ឍន៍ទីផ្សារមួយដែលមានគោលបំណងពង្រឹងការចូលរួមរបស់កសិករក្រីក្រ (ផ្តោតសំខាន់លើស្ត្រី) នៅក្នុងទីផ្សារដើម្បីធានានូវលទ្ធភាពប្រើប្រាស់ធាតុចូលកសិកម្ម និងសេវាកម្មបានប្រសើរ និងទទួលបានចំណូលខ្ពស់។ កត្តាគន្លឹះនៃវិធិសាស្ត្រនេះគឺជាដំណើរការសម្របសម្រួលមួយ សម្រាប់ទាក់ទាញការចូលរួមពីបណ្តាដៃគូឯកជន និងសាធារណៈ ព្រមទាំងអង្គការសង្គមស៊ីវិលក្នុងការផ្តល់ជូននូវទំនិញ និងសេវាកម្មនានា ទាំងធាតុចូល និងផលិតផលកសិកម្មនៃខ្សែច្រវាក់តម្លៃសាកវប្បកម្ម (ឧទាហរណ៍៖ ការផ្សព្វផ្សាយ ធាតុចូលកសិកម្ម ការរៀបចំទីផ្សារ និងព័ត៌មានទីផ្សារ) ដែលសាកសម និងបំពេញចំតម្រូវការកសិករក្រីក្រ និងអ្នកកែច្នៃ។ ឆ្លងកាត់រយៈពេល៨ឆ្នាំ យើងអាចសម្រេចបានលទ្ធផលប្រកបដោយផ្លែផ្កា។ ផលិតកម្មលើដំណាំបន្លែរបស់កម្ពុជាបានកើនឡើងគួរអោយកត់សម្គាល់ក្នុងអំឡុងពេល៣ឆ្នាំចុងក្រោយនេះ និងបច្ចុប្បន្នបានគ្របដណ្តប់ ៦៨% នៃតម្រូវការទីផ្សារក្នុងស្រុក (៧00.000តោនក្នុងឆ្នាំ២០២០) ប្រៀបធៀបនឹង៤២២.000តោន ក្នុងឆ្នាំ២០១៣។ សមិទ្ធិផលដ៏អស្ចារ្យ!

សៀវភៅមគ្គុទេសក៍ក៏សម្រាប់ការអភិវឌ្ឍប្រព័ន្ធទីផ្សារកសិកម្មនេះ គឺជាកាប្រមូលផ្តុំឧបករណ៍ គោលការណ៍ ការប្រតិបត្តិ និងវិធីសាស្ត្រនានាដែលបានអភិវឌ្ឍក្នុងអំឡុងពេលអនុវត្តន៍គម្រោងឈេន។ សៀវភៅនេះនឹងផ្តល់ជាឯកសារយោងសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងខ្សែច្រវាក់តម្លៃកសិកម្ម ដែលមកពីវិស័យឯកជន វិស័យសាធារណៈ និងសង្គមស៊ីវិលជាដើម។ ជាងនេះទៅទៀត វាក៏ជាសៀវភៅណែនាំមួយសម្រាប់ឆ្ពោះទៅរកនិរន្តរភាពដែលជាស្នូលដ៏សំខាន់សម្រាប់គម្រោងឈេនដោយមានគោលបំណងពង្រឹង ប្រព័ន្ធទីផ្សារសាកវប្បកម្ម និងសមត្ថភាពនៃតួអង្គគ្រប់វិស័យដើម្បីផ្តល់សេវាកម្មទៅកសិករគោលដៅ។ បណ្តាញទំនាក់ទំនង គោលនយោបាយ និងប្រព័ន្ធទីផ្សារដែលបានបង្កើតឡើង នឹងបន្តដំណើរជាតួអង្គពាក់ព័ន្ធគ្រប់វិស័យ ចំណែកឯកសិករនឹងអាចឈានដល់កម្រិតអប្បបរមាសមស្របមួយ ដើម្បីក្លាយជាទីផ្សារដែលទទួលបានប្រាក់ចំណេញ និងអាចទ្រទ្រង់ខ្លួនឯងបាន។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម អាជ្ញាធរដែនដីថ្នាក់ខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការអភិវឌ្ឍន៍ហូឡង់ (SNV) ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់កិច្ចសហប្រតិបត្តិការដ៏ល្អឥតខ្ចោះ និងសម្រាប់ការរួមចំណែកដ៏មមាញឹកដល់ការអនុវត្តនៃគម្រោងឈេន។

មាគុស ប័រលី (Markus Buerli)
នាយក នៃកិច្ចសហប្រតិបត្តិការ

# បុព្វកថា

គម្រោងលើកកម្ពស់ប្រាក់ចំណូល និងអាហារូបត្ថម្ភនៅកម្ពុជា (CHAIN) គឺជាកម្មវិធីអភិវឌ្ឍន៍រយៈពេលប្រាំបីឆ្នាំ ដែលគ្រប់គ្រងដោយទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ (SDC) ដើម្បីកែលម្អផលិតកម្ម និងអាជីវកម្មបន្លែរបស់កសិករខ្នាតតូចនៅក្នុងខេត្តក្រីក្រ និងដាច់ស្រយាលចំនួនបួនរបស់កម្ពុជា៖ ខេត្តឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង និងក្រចេះ។

គម្រោងឈេន (CHAIN) បានវិវឌ្ឍជាច្រើនឆ្នាំដោយសារអន្តរវស័យនេះមានភាពចាស់ទុំ។ គម្រោងឈេន (CHAIN) បានធ្វើការជាមួយតួអង្គទីផ្សារជាច្រើន (កសិករ ពាណិជ្ជករ អ្នកទិញជាតិ និងទាំងអ្នកផ្គត់ផ្គង់ធាតុចូលថ្នាក់ស្រុក និងថ្នាក់ជាតិ) ដោយនាំពួកគេរួមគ្នាក្នុងភាពជាដៃគូផ្សេងៗ ខណៈពេលដែលកំពុងសហការគ្នានៅគ្រប់កម្រិតនៃរដ្ឋាភិបាល។ ក្នុងនាមជាគម្រោងដែលមានបទពិសោធន៍ខ្ពស់ គម្រោងបានប្រើការបរាជ័យក៏ដូចជាភាពជោគជ័យរបស់វា ដើម្បីរៀន និងសម្របខ្លួន។

យើងបានដឹងថានៅប្រទេសកម្ពុជាមានការខ្វះខាតសម្ភារៈសម្រាប់វិធីសាស្រ្តជាក់ស្តែងក្នុងការអភិវឌ្ឍប្រព័ន្ធទីផ្សារកសិកម្ម។ យើងសង្ឃឹមថានឹងដោះស្រាយគម្លាតនេះ ដោយចងក្រងឯកសារបទពិសោធន៍របស់គម្រោងឈេន (CHAIN) នៅក្នុងស៊េរីនៃសៀវភៅមគ្គុទេសក៏ក៏ដែលផ្តោតលើការអនុវត្តជាក់ស្តែងនៃវិធីសាស្រ្តមួយចំនួនដែលត្រូវបានបង្កើតឡើងក្នុងអំឡុងពេលវដ្តរបស់គម្រោង។

---

## បញ្ហានីមួយៗនៅក្នុងស៊េរីនិយាយអំពីប្រធានបទមួយដូចខាងក្រោម៖

- បញ្ហានីមួយៗនៅក្នុងស៊េរីនិយាយអំពីប្រធានបទមួយដូចខាងក្រោម៖
- ការណែនាំអំពីការអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារ
- ការសម្របសម្រួលដល់ការអភិវឌ្ឍន៍បណ្តុំ
- ការសម្របសម្រួលទំនាក់ទំនង B2B
- វិធីសាស្រ្តបណ្តុះបណ្តាលកសិករគំរូ
- វិធីសាស្រ្តពន្លឿនអាជីវកម្មជនបទ
- ការអភិវឌ្ឍថវិកាសម្រាប់ដំណាំ
- វីដេអូកសិករសម្រាប់ការផ្សព្វផ្សាយឌីជីថល

---

មគ្គុទេសក៍ទាំងនេះអាចមានប្រយោជន៍សម្រាប់គំនិតផ្តួចផ្តើមខ្សែច្រវ៉ាក់តម្លៃកសិកម្មផ្សេងៗគ្នា ដោយសារគោលការណ៍ និងអន្តរាគមន៍ភាគច្រើនដែលពួកគេពិពណ៌នា គឺអាចអនុវត្តបានយ៉ាងទូលំទូលាយ។ ឯកសារទាំងនេះត្រូវបានបង្កើតឡើងសម្រាប់តួអង្គនៅក្នុងវិស័យអភិវឌ្ឍន៍កម្ពុជា ដូចជាអ្នកបច្ចេកទេសរបស់រដ្ឋាភិបាល និងបុគ្គលិកផ្នែកផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និស្សិត និងអ្នកដែលធ្វើការឱ្យក្រុមហ៊ុនផ្នែកឯកជនដែលចូលរួមដោយផ្ទាល់នៅក្នុងខ្សែច្រវ៉ាក់តម្លៃ។ យើងរំពឹងថា គន្លឹះ និងមេរៀនជាក់ស្តែងមួយចំនួន ក៏នឹងមានប្រយោជន៍សម្រាប់អ្នកអនុវត្តនៅក្រៅប្រទេសផងដែរ។ យើងសង្ឃឹមថាការអនុវត្តអនុសាសន៍ដែលមានចែងក្នុងការសៀវភៅមគ្គុទេសក៍ទាំងនេះនឹងនាំទៅរកប្រព័ន្ធអាហារដែលប្រសើរជាងមុន រួមបញ្ចូលគ្នាទាំង សមធម៌ និងនិរន្តរភាព។

យើងសូមអរគុណអ្នកទាំងអស់ដែលបានចូលរួមចំណែកក្នុងសៀវភៅមគ្គុទេសក៍ទាំងនេះដោយការសរសេរ និងការរិះគន់ ក៏ដូចជាអ្នកដែលបានអនុវត្តវិធីសាស្រ្តក្នុងការអនុវត្ត។ យើងសូមថ្លែងអំណរគុណចំពោះបុគ្គលិក គម្រោងឈេន (CHAIN) ដែលបានធ្វើការដោយមិននឿយហត់ពេញមួយឆ្នាំនៃការអនុវត្តគម្រោង ក៏ដូចជាបុគ្គលិកនៃដៃគូរបស់យើង SwissContact មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFFs) ក្នុងខេត្តគោលដៅទាំងបួន អគ្គនាយកដ្ឋានកសិកម្ម (GDA), ក្រុមហ៊ុនលក់ធាតុចូល, ក្រុមហ៊ុនគ្រាប់ពូជ, អ្នកទិញ និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក។ ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ SDC សម្រាប់ការផ្តល់មូលនិធិដល់កម្មវិធីនេះសម្រាប់រយៈពេលប្រាំបីឆ្នាំ ឆន្ទៈរបស់ពួកគេក្នុងការធ្វើកិច្ចការជាច្រើនជាមួយយើង និងការបើកចំហរបស់ពួកគេចំពោះការគ្រប់គ្រង ការសម្របខ្លួនដោយផ្អែកលើការរៀនសូត្រ និងការឆ្លុះបញ្ចាំងជាបន្តបន្ទាប់។

# តារាងមាតិកា


១. សេចក្តីផ្តើម ១

២. សារតា ២

៣. ទិដ្ឋភាពទូទៅនៃវិធីសាស្រ្ត ៣

៤. ជំហានដើម្បីអនុវត្តដំណោះស្រាយទឹកឆ្លាតវៃ (SWSs) និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ ៥

៥. ការណែនាំជាជំហានៗ ៦

៥.១ ការវាយតម្លៃស្រុក និងបញ្ជី SWS ៦

៥.២ ការសន្ទនាថ្នាក់ស្រុក ៧

៥.៣ ការវាយតម្លៃកសិដ្ឋានបុគ្គលផ្ទាល់/ការស្ទង់មតិតំបន់ ១០

៥.៤ ការជ្រើសរើស និងការអនុវត្តបច្ចេកវិជ្ជា SWS និងអាកាសធាតុឆ្លាតវៃ ១០

៥.៥ ការបណ្តុះបណ្តាលគ្រូបង្គោល/ការគាំទ្រ SME ១៣

៥.៦ ការចែករំលែកចំណេះដឹងតាមរយៈវេទិកាឌីជីថល ១៥

៦. សេចក្តីសន្និដ្ឋាន ១៦

ឧបសម្ព័ន្ធ ១៨

# ១. សេចក្តីផ្តើម

គម្រោងលើកកម្ពស់ប្រាក់ចំណូល និងអាហារូបត្ថម្ភសម្រាប់វិស័យសាកវប្បកម្មកម្ពុជា (ឈេន) បានបង្កើតសៀវភៅមគ្គុទេសក៍ (HTGs) ដែលមានន័យថាជាសៀវភៅមគ្គុទេសក៍ដែលអាចយកទៅអនុវត្តតាម និងផ្តល់ព័ត៌មានសម្រាប់អ្នកដែលមានបំណងចង់ចម្លង និងអភិវឌ្ឍបន្ថែមទៀតនូវវិធីសាស្ត្រជោគជ័យដែលបានប្រើក្នុងដំណាក់កាលទាំងបីនៃគម្រោងឈេន។ សៀវភៅមគ្គុទេសក៍(HTGs) នីមួយៗ ផ្តល់នូវទិដ្ឋភាពទូទៅនៃវិធីសាស្ត្រ ការណែនាំជាជំហានៗ គន្លឹះ និងអនុសាសន៍ និងរឿងរ៉ាវជោគជ័យមកបង្ហាញ។

យើងសង្ឃឹមថាសៀវភៅមគ្គុទេសក៍ (HTGs) ទាំងនេះនឹងមានប្រយោជន៍សម្រាប់អង្គការជាច្រើននៅទូទាំងពិភពលោក ជាពិសេសអ្នកដែលចូលរួមក្នុងគម្រោងអភិវឌ្ឍន៍កសិកម្មដែលអនុវត្តវិធីសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារ (សូមមើលប្រអប់ទី ១)។ ទោះជាយ៉ាងណាក៏ដោយ យើងបានសរសេរសៀវភៅមគ្គុទេសក៍ (HTGs) ជាមួយអ្នកពាក់ព័ន្ធកម្ពុជាដែលភាគច្រើនគឺ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) អគ្គនាយកដ្ឋានកសិកម្ម (GDA) មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFFs) និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក។

### ប្រអប់ទី១៖
### អភិវឌ្ឍន៍ប្រព័ន្ធទីផ្សារ (MSD)

វិធីសាស្ត្រ MSD គ្របដណ្តប់ប្រព័ន្ធទាំងមូលដែលនៅជុំវិញទីផ្សារ។ ក្នុងករណីវិស័យសាកវប្បកម្ម ទិដ្ឋភាពរួមនេះរួមបញ្ចូលទាំងអ្នកចូលរួមទីផ្សារពាក់ព័ន្ធទាំងអស់ («តួអង្គ» ឬ «អ្នកលេង»): កសិករដែលដាំដំណាំ អ្នកលក់រាយដែលលក់គ្រាប់ពូជ និងធាតុចូលផ្សេងទៀតដល់កសិករ ឈ្មួញដែលទិញកសិផល អ្នកលក់នៅផ្សារដែលលក់បន្លែឲ្យអ្នកប្រើប្រាស់។ វាក៏អាចរួមបញ្ចូលសេវាកម្មដែលគាំទ្រទីផ្សារចំបង ដូចជាភ្នាក់ងារផ្នែកផ្សព្វផ្សាយរបស់រដ្ឋាភិបាលដែលផ្តល់ដំបូន្មានដល់កសិករ និងស្ថាបនទីផ្សារក្នុងស្រុកដែលបង្កើតកន្លែងសម្រាប់អ្នកទិញ និងអ្នកលក់ដើម្បីជួបគ្នា។

MSD មានគោលបំណងដោះស្រាយភាពក្រីក្រដោយការកែលម្អការអនុវត្តទីផ្សារក្នុងលក្ខណៈរួមបញ្ចូល ជាពិសេសដោយការកែប្រែការលើកទឹកចិត្ត និងលក្ខណៈរបស់អាជីវកម្ម និងតួអង្គទីផ្សារផ្សេងទៀត ដើម្បីធានាបាននូវការផ្លាស់ប្តូរទ្រង់ទ្រាយធំដែលយូរអង្វែង និងមានប្រយោជន៍។

កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតនៅអាស៊ីចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ នៅគ្រប់សេណារីយ៉ូនៃការប្រែប្រួលអាកាសធាតុ សីតុណ្ហភាពជាមធ្យមនៅកម្ពុជាត្រូវបានគេរំពឹងថានឹងកើនឡើងគួរឱ្យកត់សម្គាល់។ នេះទំនងជានឹងបង្កើនបរិមាណទឹកភ្លៀងសរុប និងអាំងតង់ស៊ីតេទឹកភ្លៀង ដែលនាំឱ្យមានឱកាសខ្ពស់នៃទឹកជំនន់។ ទន្ទឹមនឹងនោះការបង្កើនគ្រោះរាំងស្ងួតនឹងកើនឡើងផងដែរ ដោយតំបន់ខ្លះជួបនឹងរដូវប្រាំងយូរជាងនេះ។ ភ្លៀងកាន់តែច្រើន និងសំណើមខ្ពស់នឹងបង្កើនជំងឺ និងសម្ពាធពីការបំផ្លាញរបស់សត្វល្អិត ហើយធ្វើឱ្យការហាលឬសំងួតព្រមទាំងការប្រមូលផលដំណាំកាន់តែពិបាក។ ការគ្រប់គ្រងធនធានទឹកនឹងកាន់តែមានសារៈសំខាន់ក្នុងការដោះស្រាយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ជាពិសេសក្នុងវិស័យសាកវប្បកម្ម។

គម្រោងឈេន (CHAIN) បានគាំទ្រការផ្លាស់ប្តូរពីការសាកវប្បកម្មលក្ខណៈគ្រួសារទៅជាសាកវប្បកម្មអាជីពសម្រាប់កសិករខ្នាតតូចជាច្រើននៅក្នុងខេត្តគោលដៅទាំងបួន។ ការផ្លាស់ប្តូរទៅកាន់ការអនុវត្តបែបអាជីវកម្មនេះ រួមមានការទទួលយកបច្ចេកវិជ្ជាផលិតកម្មឆ្លាតវៃតាមអាកាសធាតុ ការផ្សារភ្ជាប់ជាមួយនឹងបណ្តុំទីផ្សារ និងកិច្ចព្រមព្រៀងលើផែនការផលិតកម្មជាមួយអ្នកទិញ។ គម្រោងឈេនបានជំរុញអាជីវកម្មខ្នាតតូចជាច្រើន ដើម្បីផ្តល់នូវធាតុចូលត្រឹមត្រូវសម្រាប់ការផ្លាស់ប្តូរនេះ។ ខ្សែច្រវ៉ាក់ផ្គត់ផ្គង់សាកវប្បកម្មពាណិជ្ជកម្មទាមទារការផ្គត់ផ្គង់បានពេញមួយឆ្នាំ ដោយអ្នកប្រើប្រាស់ត្រូវការបន្លែជារៀងរាល់ថ្ងៃ។ ដូច្នេះការផលិតពេញមួយឆ្នាំគឺជាតម្រូវការអទិភាពដើម្បីផ្លាស់ប្តូរទីផ្សារទៅជាកម្រិតពាណិជ្ជកម្ម។ ទឹកសម្រាប់ស្រោចស្រពដំណាំតែងតែជាបញ្ហានៅរដូវប្រាំង ខណៈដែលទឹកជំនន់ និងការលិចទឹក (ជាំទឹក) ជាបញ្ហាប្រឈមនៅរដូវវស្សា។ ដោយដឹងពីតម្រូវការក្នុងការគ្រប់គ្រងទឹកឱ្យបានត្រឹមត្រូវ ដើម្បីសម្រេចបាននូវការផលិតពេញមួយឆ្នាំ ក្រុមការងារ CHAIN បានចាប់ផ្តើមធ្វើការពិសោធន៍ និងផ្សព្វផ្សាយពីដំណោះស្រាយទឹកឆ្លាតវៃ (SWSs) ដូចជាម៉ាស៊ីនបូមដោយប្រើថាមពលពីពន្លឺព្រះអាទិត្យ អាងស្តុកទឹក អណ្តូង និងអាងស្តុកទឹកសហគមន៍។ គម្រោង CHAIN បានផ្តួចផ្តើមការពិភាក្សាលើការគ្រប់គ្រងធនធានទឹកជាសមូហភាពនៅថ្នាក់ភូមិ និងស្រុក និងសហការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាមញ្ញ។ យើងក៏បានពិសោធន៍ជាមួយផ្ទះសំណាញ់តម្លៃទាប និងការដំឡើងថាមពលព្រះអាទិត្យ ក៏ដូចជាសេវាកម្មថែទាំ និងជួសជុលដែលពាក់ព័ន្ធផងដែរ។

នៅឆ្នាំ២០២០ គម្រោង ឈេន បានចាប់ផ្តើមជាមួយនឹងការវាយតម្លៃនៅទីវាលនៅក្នុងខេត្តមួយ ហើយបានធ្វើការបង្ហាញសាកល្បងនៃបច្ចេកវិជ្ជាគ្រប់គ្រងទឹកផ្សេងៗ។ ការធ្វើតេស្តជាមួយកសិករបានផ្តល់ឱ្យយើងនូវសូចនាករច្បាស់លាស់អំពីអ្វីដែលនឹងដំណើរការ កសិករចូលចិត្តអ្វីដែលពួកគេអាចមានលទ្ធភាព និងចំណេះដឹងដែលពួកគេត្រូវការ ដើម្បីគ្រប់គ្រងទឹកឱ្យកាន់តែមានប្រសិទ្ធភាព កាន់តែធន់នឹងអាកាសធាតុ និងអាចផលិតបន្លែពេញមួយឆ្នាំបាន។ សៀវភៅមគ្គុទេសក៍ (HTG) នេះសង្ខេបការរកឃើញ និងអនុសាសន៍របស់គម្រោង CHAIN លើការទទួលយក SWSs និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃដោយកសិករខ្នាតតូចកម្ពុជា។

វិធីសាស្ត្រដឹកនាំដោយកសិករ SWS គឺជាដំណើរការសម្រាប់បង្កើតដំណោះស្រាយផ្អែកលើទីផ្សារសម្រាប់ប្រព័ន្ធធារាសាស្ត្រ ការបង្វៀរទឹក ការទាញយកទឹក ការស្តុកទុក និងការរក្សាទុកទឹក។ វាត្រូវបានកំណត់ជាខ្នាតតូចក្នុងកម្រិតកសិដ្ឋាន; ការប្រើប្រាស់បច្ចេកវិជ្ជាដែលមានតម្លៃសមរម្យ; និងវិធីសាស្ត្រពីមូលដ្ឋានទៅលើ។ គម្រោងឈេនបានសហការជាមួយតួអង្គក្នុងវិស័យឯកជនថ្នាក់ស្រុក និងជាតិ ( ទាំងអាជីវកម្មចាប់ផ្តើមថ្មី និងសហគ្រិនដែលមានស្រាប់ ) ដោយភ្ជាប់ពួកគេជាមួយកសិករដើម្បីផ្សព្វផ្សាយបញ្ជីផលិតផល និងសេវាកម្ម SWS ដែលសមស្រប។ ការផ្តល់ជូននូវបញ្ជីបច្ចេកវិជ្ជាផ្សេងៗគ្នាអាចឱ្យកសិករជ្រើសរើសដំណោះស្រាយដ៏ល្អបំផុតសម្រាប់ស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ។

ដោយសារទឹកជាធនធានសមូហភាព ជារឿយៗក៏មានតម្រូវការសម្រាប់ដំណោះស្រាយការគ្រប់គ្រងធនធានសមូហភាពសម្រាប់ការស្តុកទឹក ការទាញយក និងបទប្បញ្ញត្តិ។ ដើម្បីជៀសវាងការទាញយកលើសពីធនធានទឹក និងជម្លោះក្នុងពេលខ្វះខាត នោះច្បាប់ និងសិទ្ធិអ្នកប្រើប្រាស់ត្រូវតែមានការយល់ដឹង។ ជាមួយនឹងការវិនិយោគ ជួនកាលធនធានទឹកអាចត្រូវបានពង្រឹង ជាឧទាហរណ៍ តាមរយៈការធ្វើឱ្យអាងស្តុកទឹកនៅតាមសហគមន៍កាន់តែជ្រៅ ដើម្បីស្តុកទឹកបន្ថែមទៀត។ វាមានសារៈសំខាន់ណាស់ក្នុងការកំណត់ និងយល់ព្រមថាអ្នកណានឹងរួមចំណែកដល់ការចំណាយ ហើយអ្នកណានឹងមានសិទ្ធិទាញយកទឹកមកប្រើប្រាស់។ គម្រោង ឈេន បានសហការវិនិយោគជាមួយក្រុមអ្នកប្រើប្រាស់ទឹក និងស្ថាប័នរដ្ឋាភិបាលក្នុងតំបន់ ដើម្បីបង្កើនលទ្ធភាពទទួលបានប្រភពទឹករួមសម្រាប់ស្រោចស្របក្នុងរដូវប្រាំង។

ដើម្បីទប់ទល់ និងសម្របខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ កសិករនឹងត្រូវប្រើប្រាស់បច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ។ ទាំងនេះ គឺជាអន្តរាគមន៍ដែលកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការផ្លាស់ប្តូរលក្ខណៈអាកាសធាតុលើផលិតកម្មកសិកម្ម ( ការសម្របខ្លួនទៅនឹងអាកាសធាតុ ) ស្របពេលជាមួយគ្នាកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់( ការកាត់បន្ថយផលប៉ះពាល់អាកាសធាតុ )។ នៅក្នុងគម្រោងឈេន ( CHAIN ) យើងបានផ្តោតលើរោងប្លាស្ទិក/ផ្ទះសំណាញ់ និងម៉ាស៊ីនបូមទឹកដោយប្រើពន្លឺព្រះអាទិត្យ។ រោងប្លាស្ទិក/ផ្ទះសំណាញ់អាចឱ្យកសិករគ្រប់គ្រងអាកាសធាតុ និងការពារដំណាំរបស់ពួកគេពីភ្លៀងធ្លាក់ខ្លាំង។ ម៉ាស៊ីនបូមទឹកដោយប្រើពន្លឺព្រះអាទិត្យប្រើបន្ទះសូឡាដើម្បីផ្តល់ថាមពលដល់ការទាញយកទឹក ផ្ទុយពីម៉ាស៊ីនបូមទឹកប្រើសាំង និងម៉ាស៊ូត ដូច្នេះពួកគេជៀសវាងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

# ២. សាវតា

ដំណាំសាកវប្បកម្ម គឺជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចកសិកម្មនៃប្រទេសកម្ពុជា ដោយសារការកើនឡើងនៃការប្រើប្រាស់ផ្លែឈើ និងបន្លែយ៉ាងឆាប់រហ័ស។ រហូតមកដល់ពេលថ្មីៗនេះ ជាង 50% នៃបន្លែទាំងអស់ត្រូវបាននាំចូលពីប្រទេសជិតខាង ដែលត្រូវបានផលិតដោយបច្ចេកវិជ្ជាកាន់តែប្រសើរ និងអាចផ្តល់តម្លៃប្រកួតប្រជែងខ្ពស់។ ទោះជាយ៉ាងនេះក្តី បន្លែដែលនាំចូលមានសំណល់ថ្នាំពុលច្រើន ដូច្នេះហើយបានជាមានការព្រួយបារម្ភពីបញ្ហាសុវត្ថិភាពចំណីអាហារ។ គម្រោងឈេនបានធ្វើការលើការលើកកម្ពស់បន្លែដែលផលិតក្នុងស្រុកប្រកបដោយសុវត្ថិភាពនៅក្នុងខេត្តចំនួនបួននៃភាគខាងជើងរបស់ប្រទេសកម្ពុជា ( ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង និងក្រចេះ )។

**មកដល់ពេលនេះ គម្រោងឈេនសម្រេចបានលទ្ធផលជារួមដូចខាងក្រោមតាមរយៈកិច្ចអន្តរាគមន៍ ដំណោះស្រាយទឹកឆ្លាតវៃ ( SWS ) និងអាកាសធាតុឆ្លាតវៃ៖**

- កសិករខ្នាតតូចពាក់កណ្តាលអាជីព និងអាជីពជាង ១៦០០ សម្រេចបានផលិតកម្មបន្លែពេញមួយឆ្នាំ។ កសិករបានវិនិយោគលើដំណោះស្រាយទឹកឆ្លាតវៃ ( SWS ) ផ្សេងៗរួមទាំងការបង្កើនសមត្ថភាពស្តុកទឹក ការប្រើប្រាស់បច្ចេកទេសធារាសាស្ត្រខ្នាតតូច និងធ្វើការដើម្បីរក្សាសំណើមដី។
- វគ្គបណ្តុះបណ្តាលគ្រូបង្គោល ( ToTs ) ស្តីពីការអនុវត្តទឹកឆ្លាតវៃ និងជម្រើសនៃការគ្រប់គ្រងធនធានទឹកត្រូវបានផ្តល់ជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត និងបុគ្គលិករដ្ឋបាលស្រុក ឃុំ សង្កាត់ ដែលអាចជួយដល់កសិករ។ មន្ត្រីរដ្ឋាភិបាលទាំងនេះបានពិភាក្សាជាមួយសមាជិកសហគមន៍អំពីរបៀបផ្តល់អាទិភាពដល់ការវិនិយោគក្នុងការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដែលដឹកនាំដោយកសិករនៅក្នុងផែនការវិនិយោគអភិវឌ្ឍន៍សហគមន៍របស់ពួកគេ។
- គម្រោងឈេន ( CHAIN ) បានផ្តល់ការគាំទ្រដល់កសិករជាង ២០០ នាក់ ដើម្បីសហការវិនិយោគលើប្រព័ន្ធបូមទឹកដោយប្រើពន្លឺព្រះអាទិត្យ។
- គម្រោងឈេន ( CHAIN ) បានសហការវិនិយោគលើប្រព័ន្ធធនធានទឹកសមូហភាពចំនួន ៥ ដែលផ្តល់ទឹកដល់កសិករខ្នាតតូចចំនួន ១.៥០០ នាក់ និងផ្តល់អត្ថប្រយោជន៍ដោយប្រយោលដល់ប្រជាជនចំនួន ៧.៥០០ នាក់។
- គម្រោងឈេន ( CHAIN ) បានគាំទ្រអ្នកផ្គត់ផ្គង់ SWS ថ្នាក់ស្រុក និងជាតិចំនួន ២០ ដែលភ្ជាប់ពួកគេជាមួយកសិករ។
- គម្រោងឈេន ( CHAIN ) បានគាំទ្រអាជីវកម្មខ្នាតតូចថ្នាក់ស្រុកដើម្បីផ្តល់សេវាកម្មដំឡើង និងជួសជុលគ្រឿងបរិក្ខារពន្លឺព្រះអាទិត្យ ( អាជីវកម្មចំនួន ២០ ) និងរោងផ្លាស្ទិក/ផ្ទះសំណាញ់ ( អាជីវកម្មពីរ )។
- គម្រោងឈេន ( CHAIN ) បានសម្របសម្រួលការផលិតវីដេអូដោយកសិករដើម្បីចែករំលែកបទពិសោធន៍របស់ពួកគេជាមួយមិត្តភ័ក្តិរបស់ពួកគេតាមរយៈបណ្តាញសង្គម។

# ៣. ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រ

## តើអ្វីជាបញ្ហា ?

- កសិករជាច្រើនមិនមានទឹកគ្រប់គ្រាន់ក្នុងរដូវប្រាំងដើម្បីស្រោចស្រពលើស្រែចម្ការរបស់ពួកគេ (ស្រះស្តុកទឹក ប្រសិនបើមាន ហួតតហាងជាប្រចាំក្នុងរដូវប្រាំង) ដូច្នេះហើយ ពួកគាត់មិនអាចដាំបន្លែពេញមួយឆ្នាំបានទេ។ទោះជាយ៉ាងណាក៏ដោយការដាំដុះសាកវប្បកម្មបែបអាជីវកម្មតម្រូវឱ្យមានការផលិតពេញមួយឆ្នាំដែលអាចសម្រេចបានតាមរយៈដំណោះស្រាយទឹកឆ្លាតវៃ (SWSs)។
- ការផលិតបន្លែនៅរដូវវស្សាត្រូវការការការពារពីភ្លៀងធ្លាក់ខ្លាំង ដែលបណ្តាលឱ្យខូចខាតដំណាំ និងបង្កើនការកើតជំងឺ។
- បម្រែបម្រួលអាកាសធាតុទំនងជានឹងនាំឱ្យមានការប្រែប្រួលទម្រង់អាកាសធាតុផ្សេងៗច្រើន។ ទឹកភ្លៀងមិនទៀងទាត់នឹងបង្កើនប្រូបាប៊ីលីតេនៃទឹកជំនន់ដដែលៗ និងគ្រោះរាំងស្ងួតកាន់តែយូរ។ នេះនឹងនាំឱ្យមានការពឹងផ្អែកកាន់តែខ្លាំងលើទឹកក្រោមដី និងទឹកលើផ្ទៃ។
- កសិករជាញឹកញាប់មិនដឹងអំពីជម្រើសដែលមានសម្រាប់ការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាព និងឆ្លាតវៃ រួមទាំងការបង្កើនសមត្ថភាពស្តុកទឹក ការរក្សាសំណើមដី ការប្រើប្រាស់ទឹកបម្រុងដោយនិរន្តរភាពនៃទឹកក្រោមដី និងការពង្រឹងការបញ្ចូលទឹកក្រោមដី។ សូម្បីតែនៅពេលដែលពួកគេដឹងពីដំណោះស្រាយទាំងនេះ កសិករប្រហែលជាមានចំណេះដឹងមិនគ្រប់គ្រាន់ដើម្បីជ្រើសរើសអោយបានត្រឹមត្រូវសម្រាប់កសិដ្ឋានរបស់ពួកគេទេ។
- បច្ចេកទេសដំណោះស្រាយទឹកឆ្លាតវៃ (SWSs) មិនអាចទទួលបានសេវាកម្ម ឬផលិតផលបានយ៉ាងងាយស្រួលនៅក្នុងខេត្ត/ស្រុករបស់ប្រទេសកម្ពុជានោះទេ។ មានកង្វះអ្នកផ្តល់សេវាថ្នាក់ស្រុក និងហាងដែលលក់ផលិតផលដែលអាចទុកចិត្តបាន។
- ប្រព័ន្ធស្រោចស្រពដោយប្រើម៉ាស៊ីនបូមប្រើប្រេងម៉ាស៊ូត និងសាំងមានតម្លៃថ្លៃឡើងៗ។ ដំណោះស្រាយថាមពលដោយប្រើពន្លឺព្រះអាទិត្យមានតម្លៃថោកជាង ប៉ុន្តែកសិករមិនមានទំនុកចិត្តលើពួកវាទេដោយសារបទពិសោធន៍មិនល្អជាមួយបន្ទះដែលមានតំលៃថោកងាយខូចឬមិនដំណើរការជាញឹកញាប់។ សេវាជួសជុល និងថែទាំមិនមាននៅថ្នាក់ស្រុកទេ ហើយដូច្នេះមានតម្លៃថ្លៃក្នុងការជួសជុល និងខាតពេលវេលា។
- ការវិនិយោគលើទឹកលើសពីការប្រើប្រាស់ក្នុងកសិដ្ឋានបុគ្គលត្រូវការមានដំណោះស្រាយរួម។ ការវិនិយោគលើទឹកភាគច្រើនជាគម្រោងធំថវិកាច្រើន គម្រោងពីលើចុះក្រោម សំដៅលើប្រព័ន្ធធារាសាស្ត្រដែលភាគច្រើនលើដំណាំស្រូវ។ មានការវិនិយោគតិចតួចផ្តោតលើគម្រោងប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងពីក្រោមទៅលើសម្រាប់ដំណាំដែលមានតម្លៃខ្ពស់ ឬលើតាមតំបន់ខ្ពង់រាប។

## តើយើងរំពឹងថានឹងសម្រេចបានអ្វីខ្លះ ?

- កសិករមានលទ្ធភាពប្រើប្រាស់ទឹក និងស្រោចស្រពគ្រប់គ្រាន់សម្រាប់ផលិតពេញមួយឆ្នាំ។ ទីផ្សារផ្តល់ជូននូវផលិតផល និងសេវាកម្មសមស្របជាច្រើនប្រភេទ ដើម្បីទាញយក រក្សាទុក និងផ្គត់ផ្គង់ទឹកដល់កសិដ្ឋានក្នុងតម្លៃសមរម្យ។
- កសិករម្នាក់ៗមានចំណេះដឹងជាមូលដ្ឋានក្នុងការជ្រើសរើសប្រព័ន្ធបូមត្រឹមត្រូវ និងទំហំទុយោត្រឹមត្រូវ សមត្ថភាពបូម និងទំហំអាងស្តុកទឹក។ ពួកគេអាចវិនិយោគតាមសមត្ថភាពសងវិញរបស់ពួកគេ នៅពេលដែលពួកគេបានកាត់បន្ថយថ្លៃដើមផលិតកម្ម និងបង្កើនប្រាក់ចំណេញ។
- សហគ្រាសធុនតូច និងមធ្យមថ្នាក់ស្រុកអាចដំឡើង ថែទាំ និងជួសជុលប្រព័ន្ធបូមទឹកដោយថាមពលពន្លឺព្រះអាទិត្យ និងរោងផ្លាស្ទិក ឬផ្ទះសំណាញ់។
- កសិករអាចចែករំលែកបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេជាមួយកសិករផ្សេងទៀតតាមរយៈបណ្តាញសង្គម (ដូចជា Facebook និង Telegram) ដើម្បីជំរុញការកើនឡើងទីផ្សារនៃដំណោះស្រាយទឹកឆ្លាតវៃ (SWSs) និងការផ្តល់ជូនទីផ្សារបន្ថែម។
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចជួយសម្រួលដល់ការទទួលយកបច្ចេកវិជ្ជា អាកាសធាតុឆ្លាតវៃសម្រាប់វិស័យសាកវប្បកម្ម។
- កសិករ និងសមាជិកសហគមន៍ផ្សេងទៀតអាចវិភាគស្ថានភាពទឹករបស់ពួកគេ និងយល់ព្រមលើដំណោះស្រាយរួមក្នុងការគ្រប់គ្រងធនធានទឹកប្រកបដោយសមធម៌ និងនិរន្តរភាព។

## តើមានដំណោះស្រាយ / វិធីសាស្ត្រអ្វីខ្លះ ?



១. កំណត់ដំណោះស្រាយទឹកឆ្លាតវៃ (SWSs) ដែលមាននៅថ្នាក់ស្រុក និងថ្នាក់ជាតិ។ គូរបញ្ជីផលិតផល និងអ្នកផ្គត់ផ្គង់សេវាដំណោះស្រាយទឹកឆ្លាតវៃ (SWS) ដែលអាចផ្តល់យោបល់ដល់កសិករលើការជ្រើសរើសដំណោះស្រាយដែលសមស្របនឹងស្ថានភាពរបស់ពួកគេ។



២. បង្ហាញ និងជំរុញបច្ចេកវិជ្ជាទឹកនិងអាកាសធាតុឆ្លាតវៃជាមួយកសិករតាមរយៈការសហការវិនិយោគ។ បង្ហាញកសិករនៅក្បែរអំពីរបៀបដែលកសិករសាកល្បងអាចទទួលបាន និងការទាញយកទឹកគ្រប់គ្រាន់ក្នុងរដូវប្រាំង ស្រោចស្រពពេញមួយឆ្នាំ និងអនុវត្តការរក្សាសំណើមដីដោយប្រើ SWSs ។



៣. បង្ហាញពីការដំឡើងរោងផ្ទាស្ទិកនិងម៉ាស៊ីនបូមទឹកដោយប្រើពន្លឺព្រះអាទិត្យដែលមានតម្លៃទាប និងបង្កើតអាជីវកម្មដំឡើង និងជួសជុលថ្នាក់ស្រុកសម្រាប់ប្រភេទឧបករណ៍ទាំងនេះ។



៤. បង្ហាញ និងសហការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសមូហភាពសម្រាប់ការស្តុកទឹក និងការគ្រប់គ្រងធនធានទឹក។



៤. ផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោល (ToTs) ដល់បុគ្គលិកផ្នែកផ្សព្វផ្សាយរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល/អ្នកសម្របសម្រួលវាល ដែលអាចផ្តល់យោបល់ដល់កសិករអំពីជម្រើសសមស្រប។



៥. ការបញ្ជ្រាបបញ្ចូលទៅលើផែនការ និងថវិកាអភិវឌ្ឍន៍មូលដ្ឋាន ដើម្បីរួមបញ្ចូលអន្តរាគមន៍ដំណោះស្រាយទឹកឆ្លាតវៃ (SWS) ខ្នាតតូច។



៦. លើកទឹកចិត្ត និងបណ្តុះបណ្តាលកសិករឱ្យចែករំលែកបទពិសោធន៍ដំណោះស្រាយទឹកឆ្លាតវៃ (SWS) របស់ពួកគេតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម (Facebook, Telegram និង YouTube) ជាពិសេសតាមរយៈវីដេអូដែលថតជាមួយទូរស័ព្ទស្មាតហ្វូន។

# ៤. ជំហានដើម្បីអនុវត្តដំណោះស្រាយទឹកឆ្លាតវៃ (SWSs) និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

កសិករត្រូវទទួលបានទឹកគ្រប់រដូវ ហើយប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព ដើម្បីអាចផលិត និងផ្គត់ផ្គង់បន្លែពេញមួយឆ្នាំដល់អ្នកទិញ។ អ្នកសម្របសម្រួល និងមន្ត្រីផ្នែកផ្សព្វផ្សាយគួរតែយល់អំពីស្ថានភាពជាក់លាក់របស់កសិករនីមួយៗ និងបញ្ហាប្រឈមចម្បងរបស់ពួកគេ ដើម្បីកំណត់អត្តសញ្ញាណដំណោះស្រាយទឹករួមគ្នា។ ខាងក្រោមនេះ គឺជាជំហានមួយចំនួនដើម្បីវាយតម្លៃស្ថានភាពទឹករបស់កសិករ វិភាគបញ្ហា និងបញ្ហាប្រឈម និងកំណត់អត្តសញ្ញាណតួអង្គសំខាន់ៗដែលត្រូវការដើម្បីដោះស្រាយបញ្ហាទាំងនោះប្រកបដោយនិរន្តរភាព។

| | ជំហានវិធីសាស្ត្រ | គោលបំណង | លទ្ធផល |
|---|---|---|---|
| 1 | **ការវាយតម្លៃថ្នាក់ស្រុកជាបឋម និងបញ្ជីបច្ចេកវិជ្ជា SWS/អាកាសធាតុឆ្លាតវៃ** | • អង្កេតភាពអាចរកបាននៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃផ្សេងៗគ្នា និងអ្នកផ្គត់ផ្គង់ និងតម្លៃរបស់ពួកគេ។<br>• ស្វែងយល់ពីការប្រែប្រួលអាកាសធាតុ និងបញ្ហាគ្រប់គ្រងទឹកសំខាន់ៗនៅក្នុងស្រុក។ | • ព័ត៌មានទូទៅអំពី SWSs<br>• បញ្ជី SWS និងជម្រើសអាកាសធាតុឆ្លាតវៃ<br>• បញ្ជីអ្នកផ្គត់ផ្គង់ជាមួយតម្លៃកំណត់ |
| 2 | **ការសន្ទនាថ្នាក់ស្រុក** | • គាំទ្រភាគីពាក់ព័ន្ធក្នុងការយល់ដឹងអំពីបញ្ហាប្រឈមទឹក និងអាកាសធាតុសំខាន់ៗនៅថ្នាក់ស្រុក។<br>• រួមគ្នាកំណត់ដំណោះស្រាយដែលអាចកើតមាន និងជម្រើសនៃការវិនិយោគ។ | • ព័ត៌មានអំពី SWSs ថ្នាក់ស្រុក បញ្ហាអាកាសធាតុ ដំណោះស្រាយសក្តានុពល អ្នកពាក់ព័ន្ធ និងអ្នកផ្តល់សេវា<br>• គំនិតផ្តួចផ្តើមគម្រោង<br>• បញ្ជីឈ្មោះកសិករចាប់អារម្មណ៍ |
| 3 | **ការវាយតម្លៃកសិដ្ឋាននីមួយៗ / ការស្ទង់មតិក្នុងតំបន់** | តាមរយៈការពិភាក្សាជាមួយកសិករម្នាក់ៗ កំណត់បញ្ហាសម្រាប់កសិដ្ឋាននីមួយៗ និងកំណត់ដំណោះស្រាយដ៏ល្អបំផុតដើម្បីសម្រេចបាននូវផលិតកម្មពេញមួយឆ្នាំ។ សម្រាប់ដំណោះស្រាយសមូហភាព ការស្ទង់មតិទីតាំង និងការចំណាយលើហេដ្ឋារចនាសម្ព័ន្ធសមូហភាពគួរតែត្រូវបានធ្វើ ក៏ដូចជាការវាយតម្លៃអំពីឆន្ទៈរបស់អ្នកពាក់ព័ន្ធក្នុងការរួមចំណែក ឬចំណាយសម្រាប់ការថែទាំ។ | ដំណោះស្រាយដែលអាចសម្រេចបាន និងការប៉ាន់ប្រមាណនៃការចំណាយវិនិយោគសរុប |
| 4 | **ការជ្រើសរើសបច្ចេកវិជ្ជា SWS និងអាកាសធាតុ ឆ្លាតវៃ និងការវិនិយោគរួមគ្នា** | យល់ស្របជាមួយកសិករគំរូ ឬអ្នកទទួលយកបច្ចេកវិជ្ជាដំបូងដើម្បីអនុវត្ត SWS ឬដំណោះស្រាយអាកាសធាតុឆ្លាតវៃ ដែលអាចដើរតួជាការបង្ហាញដល់កសិករផ្សេងទៀតអំពីលទ្ធភាពជោគជ័យនៃបច្ចេកវិជ្ជា។ អនុញ្ញាតឱ្យកសិករ ឬសហគមន៍ជ្រើសរើស SWS និងអ្នកផ្គត់ផ្គង់ ពីបញ្ជី។ | • ចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគ<br>• ការដំឡើងដំណោះស្រាយដើម្បីបម្រើជាការបង្ហាញសាកល្បង<br>• អ្នកផ្គត់ផ្គង់ក្នុងស្រុកចុះកិច្ចសន្យា និងគាំទ្រដើម្បីពង្រីកប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។ |
| 5 | **ការបណ្តុះបណ្តាលគ្រូបង្គោល / ការគាំទ្រ SME** | បណ្តុះបណ្តាលបុគ្គលិកផ្នែកផ្សព្វផ្សាយលើការអនុវត្ត SWS ផ្សេងៗ និងរបៀបបង្កើតដំណោះស្រាយសមស្របដោយផ្អែកលើទំហំកសិដ្ឋាន តម្រូវការទឹក លទ្ធភាពទទួលបានទឹក និងការវិនិយោគ/សមត្ថភាពសងត្រលប់។ សហគ្រាសធុនតូច និងមធ្យមដែលលក់បច្ចេកវិជ្ជា SWS អាចត្រូវបានបណ្តុះបណ្តាលជំនាញបច្ចេកទេស និងអាជីវកម្ម ដើម្បីពង្រីកទីផ្សាររបស់ពួកគេ។ | • ក្រុមអ្នកជំនាញផ្នែកផ្សព្វផ្សាយ កសិករគំរូ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការក្រៅរដ្ឋាភិបាលថ្នាក់ស្រុក ដែលមានសមត្ថភាពវិភាគបញ្ហាទឹក និងណែនាំដំណោះស្រាយត្រឹមត្រូវដល់កសិករ<br>• សហគ្រាសធុនតូច និងមធ្យមបានគាំទ្រដើម្បីពង្រីកការផ្តល់ជូនរបស់ពួកគេ និងការគ្របដណ្តប់តំបន់ |
| 6 | **ការរៀន និងចែករំលែករបស់កសិករដោយប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម** | • ផ្តល់ការបណ្តុះបណ្តាលជាវីដេអូដល់បុគ្គលិកផ្នែកផ្សព្វផ្សាយ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកសិករ។<br>• រៀបចំដំណើរទស្សនកិច្ចសិក្សារវាងកសិករ និងឆ្លងស្រុក។ | • វីដេអូដែលបានចែករំលែកតាមរយៈ Telegram, Facebook និង YouTube<br>• បង្កើនការរៀនសូត្រតាមរយៈការសង្កេត (ការមើលឃើញគឺជាការជឿ) |

# ៥. ការណែនាំជាជំហាន។

## ៥.១ ការវាយតម្លៃស្រុក និងបញ្ជី SWS

### ការវាយតម្លៃថ្នាក់ស្រុក

ប្រសិនបើស្ថាប័នរបស់អ្នកធ្វើការនៅក្នុងតំបន់នោះរួចហើយ អ្នកប្រហែលជាដឹងពីទិដ្ឋភាពទូទៅដ៏ល្អអំពីបញ្ហាប្រឈមដែលកសិករជួបប្រទះទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងធនធានទឹក។ បើមិនដូច្នេះទេ ធ្វើការសិក្សារហ័ស ឬការវាយតម្លៃយ៉ាងឆាប់រហ័សអំពីសហគមន៍កសិកម្មថ្នាក់ស្រុក ប្រព័ន្ធកសិកម្មរបស់ពួកគេ ការប្រើប្រាស់ទឹកបច្ចុប្បន្ន និងបញ្ហាប្រឈមនឹងទឹក និងអាកាសធាតុ។ សិក្សាទិន្នន័យបន្ទាប់បន្សំ និងការបោះពុម្ពផ្សាយ ហើយធ្វើការសម្ភាសន៍ព័ត៌មានសំខាន់ៗជាមួយកសិករ អង្គការក្រៅរដ្ឋាភិបាល បុគ្គលិកមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (PDAFF) និង មន្ទីរធនធានទឹក និងឧតុនិយម(PDWRAM) និងមន្ត្រីរដ្ឋាភិបាលក្នុងតំបន់។ រៀបចំបទបង្ហាញជារូបភាពយ៉ាងសាមញ្ញអំពីការរកឃើញរបស់អ្នក បន្ទាប់មកពិភាក្សាជាមួយមន្ទីរពាក់ព័ន្ធខេត្តដើម្បីធ្វើការផ្ទៀងផ្ទាត់។ (សូមមើលឧបសម្ព័ន្ធទី 1 សម្រាប់បញ្ជីប្រធានបទដែលបានស្នើសម្រាប់ការវាយតម្លៃ)។

**ជាមួយនឹងព័ត៌មានដែលប្រមូលបាន អ្នកអាចដាក់ពិន្ទុស្រុកនីមួយៗនៅក្នុងតំបន់គោលដៅលើលក្ខណៈវិនិច្ឆ័យចំនួនបួន៖**

១. លទ្ធភាពបច្ចេកទេសនៃដំណោះស្រាយ រួមទាំងធនធានទឹកដែលមាន។

២. លទ្ធភាពសេដ្ឋកិច្ច ពោលគឺថាតើការវិនិយោគនឹងមានផលចំណេញមកវិញដែរឬទេ។

៣. ការលើកទឹកចិត្ត ឬចំណាប់អារម្មណ៍ដែលបង្ហាញដោយអាជ្ញាធរ និងអ្នកពាក់ព័ន្ធ ដើម្បីធ្វើការលើបញ្ហាទាំងនេះ។

៤. សក្តានុពលនៃផលប៉ះពាល់ដោយគិតគូរពីចំនួនមនុស្ស និងផ្ទៃដី (គិតជាហិកតា) ដែលអាចមានផលប៉ះពាល់។

### បញ្ជីសារពើភ័ណ្ឌអ្នកផ្គត់ផ្គង់ SWS និងបញ្ជីជម្រើស

បង្កើតបញ្ជីសារពើភណ្ឌគំរូនៃហាង និងអ្នកផ្គត់ផ្គង់បច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ និងអ្នកផ្តល់សេវានៅថ្នាក់ស្រុក ឬខេត្ត។ ពេលខ្លះអ្នកអាចទទួលបានបញ្ជីបែបនេះពីក្រសួងពាណិជ្ជកម្ម បើមិនដូច្នេះទេអ្នកអាចប្រមូលព័ត៌មាននេះតាមរយៈការសម្ភាសន៍ជាមួយម្ចាស់ហាងលក់គ្រឿងម៉ាស៊ីន អ្នកលក់ធាតុចូលកសិកម្ម ហាងលក់សម្ភារៈ និងអ្នកលក់ម៉ាស៊ីនបូមទឹក។ សួរក្រុមហ៊ុនថ្នាក់ជាតិ ប្រសិនបើពួកគេមានអ្នកចែកចាយនៅក្នុងខេត្តហើយ។ ក្រុមហ៊ុនផ្តល់សេវា រួមមានក្រុមហ៊ុនជីកអណ្តូង និងក្រុមហ៊ុនសំណង់ស៊ីវិលដែលមានគ្រឿងចក្រជីក និងកាយដី។ ជាធម្មតា ហាង ឬអ្នកផ្គត់ផ្គង់ចំនួនពីរក្នុងមួយប្រភេទនឹងផ្តល់ឱ្យអ្នកនូវព័ត៌មានគ្រប់គ្រាន់។ សួរពាណិជ្ជករអំពីផលិតផល សេវាកម្មរបស់ពួកគេ តម្លៃស្តង់ដារគុណភាព ជាដើម។ សាកសួរផងដែរអំពីបញ្ហាប្រឈមរបស់ពួកគេក្នុងនាមជាសហគ្រាស ហើយសួរគំនិតអំពីរបៀបពង្រីកអាជីវកម្មរបស់ពួកគេ។ សូមធ្វើបញ្ជីអ្នកផ្គត់ផ្គង់ក្នុងស្រុកទាំងអស់ដែលអ្នកជួប និងព័ត៌មានលម្អិតទំនាក់ទំនងរបស់ពួកគេ។

បន្ទាប់ពីអ្នកបានចងក្រងបញ្ជីសារពើភណ្ឌអ្នកផ្គត់ផ្គង់ សូមធ្វើបញ្ជី SWSs ទាំងអស់ដែលអាចរកបាន និងមានសក្តានុពល និងដំណោះស្រាយអាកាសធាតុឆ្លាតវៃ។ សូមធ្វើបញ្ជី SWSs និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃទាំងអស់នៅក្នុងឯកសារតែមួយ ដូច្នេះការបង្កើតបញ្ជីជម្រើស ធ្វើឱ្យវាកាន់តែងាយស្រួលសម្រាប់បុគ្គលិកផ្នែកផ្សព្វផ្សាយក្នុងការពន្យល់ដល់កសិករពីរបៀបដែលបច្ចេកវិជ្ជាផ្សេងៗដំណើរការដើម្បីកែលម្អលទ្ធភាពប្រើប្រាស់ទឹក ការប្រើប្រាស់ទឹក និងការអភិរក្ស។ បញ្ជីនេះក៏អនុញ្ញាតឱ្យមានការប្រៀបធៀបតម្លៃក្នុងចំណោមអ្នកផ្គត់ផ្គង់ផងដែរ ដូច្នេះកសិករអាចស្វែងរកផលិតផល និងសេវាកម្មដែលមានតម្លៃសមរម្យ និងប្រកួតប្រជែងបំផុត។

**នៅក្នុងបញ្ជី បច្ចេកវិជ្ជា SWS និងអាកាសធាតុឆ្លាតវៃអាចត្រូវបានបែងចែកជាប្រាំប្រភេទ៖**

១. ទទួលបានទឹក៖ ស្រះជីក ស្រទាប់ស្រះ អណ្តូងខួង ទំនប់ស្ទាក់ទឹកតូចៗ តាមបណ្តោយផ្លូវទឹកធម្មជាតិ អូរ។

២. ការទាញយកទឹក៖ ម៉ាស៊ីនបូមទឹក ម៉ាស៊ីនបូមទឹកអគ្គិសនី ម៉ាស៊ីនបូមទឹក ម៉ាស៊ូត/សាំង ម៉ាស៊ីនបូមទឹកប្រើថាមពលពន្លឺព្រះអាទិត្យ។

៣. ការប្រើប្រាស់ទឹក៖ ទុយោ PE/PVC, ទុយោបត់បាន, ទុយោដំណក់ទឹក, ប្រព័ន្ធសាចទឹកភ្លៀង, ទុយោទឹកភ្លៀង។

៤. ការរក្សាសំណើមដី៖ កៅស៊ូគ្របរងផ្លាស្ទិក គម្របដីសរីរាង្គ ជីកំប៉ុស្ត៍ ដំណាំគម្របដី ឧបករណ៍បញ្ហា និងគ្រប់គ្រងសញ្ញាសំណើមដី។

៥. ការគ្រប់គ្រងមីក្រូអាកាសធាតុ៖ រោងផ្លាស្ទិក ឬផ្ទះសំណាញ់ ប្រព័ន្ធអ៊ីដ្រូប៉ូនិច ដំបូលការពារ ការការពារខ្យល់កន្ត្រាក់

# ព័ត៌មានជំនួយ



**១.** ការសម្ភាសន៍អ្នកផ្គត់ផ្គង់លើផលិតផល និងសេវាកម្មជាពិសេសតម្លៃ វាអាចជាបញ្ហាប្រឈមដែរ។ អ្នកផ្គត់ផ្គង់ប្រហែលជាមិនចង់បញ្ចេញព័ត៌មាននេះទេ លុះត្រាតែអ្នកត្រៀមខ្លួនទិញផលិតផលរបស់ពួកគេភ្លាមៗ។ ដូច្នេះអ្នកគួរតែជូនដំណឹងដល់អ្នកផ្តល់សេវាឱ្យបានច្បាស់លាស់ អំពីគោលបំណងនៃការប្រមូលទិន្នន័យនេះ៖ វានឹងជួយផ្សព្វផ្សាយហាង ឬសេវាកម្មរបស់ពួកគេដល់សហគមន៍កសិកម្ម និងបើកឱកាសសម្រាប់ការវិនិយោគរួមគ្នាដោយកសិករ និងគម្រោង។

**២.** ជ្រើសរើសពេលវេលាសមស្របដើម្បីនិយាយជាមួយអ្នកផ្តល់សេវា ដូចជាពេលរសៀល ដែលជាធម្មតាពួកគេមិនសូវរវល់ក្នុងការជួបជាមួយអតិថិជន។ សុំការអនុញ្ញាតជាមុន ដើម្បីថតរូបហាង និងផលិតផលរបស់ពួកគេ។

**៣.** សួរអ្នកផ្តល់សេវាថាតើពួកគេចាប់អារម្មណ៍ក្នុងការផ្តល់ជូននូវការធ្វើបង្ហាញ ចូលរួមក្នុងការប្រជុំបណ្តុំ ឬវេទិការបស់កសិករ ឬសហការវិនិយោគក្នុងយុទ្ធនាការទីផ្សារ។ ជូនដំណឹងដល់ពួកគេអំពីកិច្ចសន្ទនាថ្នាក់ស្រុក/ខេត្តនាពេលខាងមុខផងដែរ។

**៤.** ពេលខ្លះ ការទាក់ទងអ្នកផ្តល់សេវា និងអាជីវកម្មមកពីខេត្តផ្សេងទៀត ហើយអញ្ជើញពួកគេឱ្យចូលរួមកិច្ចប្រជុំកសិករដើម្បីពិភាក្សាអំពីការវិនិយោគ SWS អាចបង្កើតការប្រកួតប្រជែង និងតម្លៃទាប។

សូមមើល**ឧបសម្ព័ន្ធ ២** សម្រាប់បញ្ជីនៃបច្ចេកវិជ្ជាសក្តានុពល។



## ៥.២ ការសន្ទនាថ្នាក់ស្រុក

កិច្ចសន្ទនាថ្នាក់ស្រុក គឺជាកិច្ចប្រជុំពហុភាគីនៅថ្នាក់ស្រុក ដើម្បីពិភាក្សាអំពីបញ្ហាទឹក និងអាកាសធាតុ និងកំណត់ដំណោះស្រាយ។ គោលបំណងសំខាន់នៃកិច្ចសន្ទនា គឺដើម្បីស្វែងយល់អំពីបញ្ហាទឹក និងអាកាសធាតុកាន់តែប្រសើរ ប្រមូលព័ត៌មានពាក់ព័ន្ធ ភ្ជាប់ទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ និងបង្កើតដំណោះស្រាយសក្តានុពល។ ដំណោះស្រាយដែលបានស្នើឡើងអាចត្រូវបានសាកល្បងតាមរយៈការសហការវិនិយោគដែលពាក់ព័ន្ធនឹងកសិករដែលចាប់អារម្មណ៍ រដ្ឋាភិបាលមូលដ្ឋាន វិស័យឯកជន និងគម្រោង។ ក្រោយមក លទ្ធផលនៃការសាកល្បងទាំងនេះអាចត្រូវបានបង្ហាញ និងពិភាក្សាជាមួយអ្នកធ្វើគោលនយោបាយនៅថ្នាក់ខេត្ត តាមរយៈសិក្ខាសាលាចែករំលែកចំណេះដឹងតាមខេត្ត។



## គោលបំណងជាក់លាក់រួមមានដូចខាងក្រោម៖

១. ចូលរួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងវិស័យសាធារណៈ និងឯកជន និងដៃគូអភិវឌ្ឍន៍ ក្នុងការពិភាក្សាអំពីឧបសគ្គទឹកចំពោះផលិតកម្មសាកវប្បកម្មពេញមួយឆ្នាំ និង SWSs ដែលពាក់ព័ន្ធ។

២. ស្វែងរកកិច្ចសហការរវាងវិស័យឯកជន និងរដ្ឋាភិបាល/អ្នកធ្វើគោលនយោបាយ និងកំណត់ដំណោះស្រាយរួមដែលមានសក្តានុពល ដើម្បីដោះស្រាយឧបសគ្គបរិស្ថានអំណោយផល។

៣. កំណត់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យទឹក ដែលអាចផ្តល់សេវាកម្ម (ខួងអណ្តូង ជីកស្រះ ជួសជុលអណ្តូង និងផលិតផល (ប្រព័ន្ធដំណក់ទឹក ឬក៏ប្រព័ន្ធបាញ់ទឹក អាងទឹក ទុយោ និងអណ្តូង) និងភ្ជាប់ពួកគេទៅនឹងកសិករអភិវឌ្ឍន៍សក្តានុពលទីផ្សារពេញលេញ។

៤. សម្របសម្រួលទំនាក់ទំនងរវាងអ្នកលក់បន្លែ និងក្រុមអ្នកផលិត/កសិករ ដើម្បីស្វែងរកទំនាក់ទំនងទីផ្សារ និងធ្វើកិច្ចព្រមព្រៀងតម្លៃដែលនឹងផ្តល់ឱ្យកសិករនូវទំនុកចិត្តដើម្បីធ្វើការវិនិយោគ SWS ចាំបាច់។

## យល់ព្រមជាមួយអាជ្ញាធរមូលដ្ឋានលើកិច្ចសន្ទនា និងអញ្ជើញភាគីពាក់ព័ន្ធ

បញ្ជាក់ពីចំណាប់អារម្មណ៍របស់អាជ្ញាធរមូលដ្ឋាន (នៅថ្នាក់ភូមិ ឃុំ និងស្រុក) ដើម្បីធ្វើអ្វីមួយអំពីបញ្ហាប្រឈមនឹងទឹក។ ស្នើឱ្យមានការសន្ទនាថ្នាក់ស្រុក និងយល់ព្រមលើទីកន្លែង អ្នកចូលរួម និងកាលបរិច្ឆេទ។ ទុកកញ្ចប់ថវិកាតូចមួយសម្រាប់អាហារសម្រន់ និងភេសជ្ជៈ។

គាំទ្រដល់អាជ្ញាធរមូលដ្ឋានក្នុងការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធទាំងអស់ និងផ្ញើលិខិតអញ្ជើញ។ ភាគីពាក់ព័ន្ធគឺ (1) តួអង្គក្នុងវិស័យសាធារណៈដូចជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (PDAFF), មន្ទីរធនធានទឹក និងឧតុនិយម (PDWRAM), និងមន្ទីរកិច្ចការនារី (PDoWA), មន្ទីរពាណិជ្ជកម្ម (PDoC) និងមន្ទីរបរិស្ថាន (PDoE); (2) តួអង្គក្នុងវិស័យឯកជន ដូចជាសហគ្រាសធុនតូច និងមធ្យមដែលផ្គត់ផ្គង់ធាតុចូល SWS អ្នកទិញបន្លែ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs); (៣) អង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍ និង (៤) ផលិតករ/កសិករ។

## ការសន្ទនាថ្នាក់ស្រុក

គោលបំណងនៃកិច្ចសន្ទនានេះ គឺដើម្បីកំណត់ និងពិភាក្សាអំពីបញ្ហាប្រឈមទឹកសំខាន់ៗដែលភាគីពាក់ព័ន្ធទាំងអស់ជួបប្រទះ ជាពិសេសបញ្ហាដែលប៉ះពាល់ដល់ផលិតកម្មសាកវប្បកម្មពេញមួយឆ្នាំ និងដើម្បីស្វែងរកដំណោះស្រាយពាក់ព័ន្ធនឹងអន្តរាគមន៍ទឹកឆ្លាតវៃ។ នៅថ្ងៃនៃកិច្ចសន្ទនា (សូមមើលឧបសម្ព័ន្ធទី 3 សម្រាប់របៀបវារៈគំរូ) សុន្ទរកថាបើក និងការណែនាំអាចត្រូវបានបន្តដោយបទបង្ហាញខ្លីៗដោយភ្នាក់ងារផ្នែកផ្សព្វផ្សាយថ្នាក់ស្រុក (PDAFF ឬ PDWRAM) ដើម្បីបញ្ជាក់ពីឧបសគ្គបច្ចេកទេស និងដំណោះស្រាយដែលបានស្នើឡើងក្នុងការគ្រប់គ្រងទឹកឆ្លាតវៃក្នុងអំឡុងពេល រដូវប្រាំង និងរដូវវស្សា។ បទបង្ហាញនឹងជួយបង្ហាញពីការយល់ដឹង ការប្តេជ្ញាចិត្ត និងសមិទ្ធផលនៃវិស័យសាធារណៈក្នុងការគ្រប់គ្រងទឹកសម្រាប់កសិកម្ម។

កម្មវិធីបន្ទាប់នៅលើរបៀបវារៈអាចជាបទបង្ហាញខ្លីៗដោយបុគ្គលិកគម្រោងអំពីការរកឃើញនៃការវាយតម្លៃថ្នាក់ស្រុកដែលបានធ្វើឡើងពីមុន រួមទាំងការណែនាំអំពីបញ្ជី SWS អមដោយផ្នែកទំនាក់ទំនងដំបូងនៃកិច្ចសន្ទនា - វគ្គបំផុសគំនិតអំពីបញ្ហាប្រឈមទឹក។ ជំហានបន្ទាប់ គឺសម្រាប់អ្នកចូលរួមក្នុងការពិភាក្សាជាក្រុមតូចៗ ដោយមានតំណាងចម្រុះពីក្រុមភាគីពាក់ព័ន្ធនីមួយៗ ដើម្បីកំណត់ដំណោះស្រាយសមស្រប អ្នកណាគួរផ្តល់ហិរញ្ញប្បទានដល់ពួកគេ របៀបទទួលខុសត្រូវក្នុងចំណោមតួអង្គគួរតែបែងចែក និងកំណត់ការទំនាក់ទំនង/កិច្ចសហប្រតិបត្តិការរវាងតួអង្គ។

បន្ទាប់ពីការពិភាក្សាជាក្រុម ធ្វើសម័យប្រជុំពេញអង្គ ដើម្បីបង្ហាញសេចក្តីសន្និដ្ឋានសំខាន់ៗ និងប្រមូលផ្តុំនូវអនុសាសន៍ និងផែនការសកម្មភាពទាំងអស់ ដោយមានរយៈពេលសួរ-ចម្លើយនៅចុងបញ្ចប់នៃកិច្ចប្រជុំពេញអង្គ។ បន្ទាប់មកអ្នកសម្របសម្រួល ផ្គូផ្គងក្រៅផ្លូវការដែលពាណិជ្ជករ និងអ្នកផ្គត់ផ្គង់ SWS អាចជួបជាមួយក្រុមកសិករនីមួយៗ ឬសហគមន៍ ដើម្បីពិភាក្សាអំពីដំណោះស្រាយសមស្រប និងវាយតម្លៃថាតើកសិករប៉ុន្មាននាក់នឹងចាប់អារម្មណ៍ក្នុងការវិនិយោគលើ SWSs ។ នេះនឹងផ្តល់ឱ្យអ្នកគ្រប់គ្នានូវគំនិតនៃតម្រូវការសម្រាប់ផលិតផល និងសេវាកម្ម SWS នៅតាមតំបន់នីមួយៗ ដោយផ្អែកលើការបន្ថែមសក្តានុពលនៃរដូវកាលរីកលូតលាស់ និងការពង្រីកតំបន់ដែលកំពុងលូតលាស់ដែលបើកដោយការវិនិយោគនៅក្នុង SWSs។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំបូកសរុប សូមសង្ខេបការពិភាក្សា និងស្នើជំហានបន្ថែមទៀត។ នៅចុងបញ្ចប់នៃកម្មវិធីនេះ កសិករដែលចាប់អារម្មណ៍លើការសហការវិនិយោគទឹកឆ្លាតវៃអាចចុះឈ្មោះជាមួយឈ្មោះ ទីតាំង លេខទំនាក់ទំនង ប្រភេទនៃអន្តរាគមន៍ SWS ដែលពួកគេត្រូវការ និងចំនួនទឹកប្រាក់ដែលពួកគេមានឆន្ទៈក្នុងការវិនិយោគ។ បញ្ជីនេះអាចត្រូវបានបញ្ជាក់ក្នុងអំឡុងពេលនៃការវាយតម្លៃកសិដ្ឋានបុគ្គល (សូមមើលផ្នែក ៥.៣)។ ប្រសិនបើកសិករមួយចំនួនចាប់អារម្មណ៍លើ SWS ជាក់លាក់មួយ អ្នកអាចរៀបចំដំណើរទស្សនកិច្ចសិក្សាទៅកាន់កសិករមួយចំនួនដែលបានអនុវត្ត SWS នោះរួចហើយ។



### បទពិសោធន៍កសិករ SWS៖
### ការសន្ទនាអំពីទឹកប្រើប្រាស់ថ្នាក់ស្រុក

អ្នកស្រី ហាន ជឿន កសិកររស់នៅខេត្តព្រះវិហារបានផលិតបន្លែដោយប្រើម៉ាស៊ីនបូមទឹកប្រើប្រេងម៉ាស៊ូត។ ម៉ាស៊ីនបូមទឹករបស់គាត់ខូចជាញឹកញាប់ ដែលរំខានដល់កម្មវិធីស្រោចស្រពដំណាំរបស់គាត់។ «វាពិបាកណាស់ ព្រោះខ្ញុំមិនមានទំនុកចិត្តក្នុងការធ្វើកិច្ចសន្យាជាមួយអ្នកទិញបន្លែរបស់ខ្ញុំ ដោយសារខ្ញុំមិនអាចធានាការផ្គត់ផ្គង់បាន។ ដំណាំរបស់ខ្ញុំច្រើនរងការខូចខាតជាញឹកញាប់ដោយសារតែគ្មានទឹកស្រោច ដែលបណ្តាលមកពីការពន្យារពេលជួសជុលម៉ាស៊ីនរបស់ខ្ញុំ»។ គាត់បានចូលរួមក្នុងកិច្ចសន្ទនាពិភាក្សាអំពីទឹកថ្នាក់ស្រុកដែលផ្តួចផ្តើមដោយគម្រោង CHAIN ដែលគាត់អាចពិភាក្សាអំពីបញ្ហាទឹករបស់គាត់។ គាត់បានរៀនអំពីដំណោះស្រាយបូមទឹកដោយប្រើសូឡា ហើយបានវិនិយោគ ១.៨០០ ដុល្លារ ជាមួយនឹងការវិនិយោគរួមគ្នារបស់គម្រោង CHAIN ចំនួន ៥០០ ដុល្លារ ដើម្បីទិញប្រព័ន្ធបូមទឹកដោយប្រើសូឡា។ ម៉ាស៊ីនបូមទឹងប្រើសូឡាអាចបញ្ជូនទឹកទៅស្រោចស្រពកសិដ្ឋានរបស់គាត់រហូតដល់ ២៥ ម៉ែត្រគូប/ថ្ងៃ។ ដោយសារគាត់មានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពដំណាំ ពេលនេះគាត់អាចបំពេញតម្រូវការអ្នកទិញ និងផ្គត់ផ្គង់បានជាប់លាប់។

# ៥.៣ ការវាយតម្លៃកសិដ្ឋានបុគ្គលផ្ទាល់/ការស្ទង់មតិតំបន់

ការវាយតម្លៃកសិដ្ឋានបុគ្គលដែលត្រូវការដើម្បីយល់ពីតម្រូវការជាក់លាក់របស់កសិដ្ឋាននៃ SWS និងផ្តល់ឱ្យកសិករនូវជម្រើស SWS ផ្សេងៗ។ ការចំណាយលើការវិនិយោគ និងលទ្ធភាពហិរញ្ញវត្ថុនៃដំណោះស្រាយនីមួយៗអាចត្រូវបានគណនា។ ការវាយតម្លៃកសិដ្ឋានគួរតែធ្វើឡើងជាមួយកសិករដែលបង្ហាញចំណាប់អារម្មណ៍លើការសហការវិនិយោគ។ កសិករក៏អាចត្រូវបានជ្រើសរើសតាមរយៈបណ្តាញផ្សេងទៀត ដូចជាមន្ត្រីផ្នែកផ្សព្វផ្សាយរបស់រដ្ឋាភិបាលក្នុងតំបន់ អង្គការក្រៅរដ្ឋាភិបាល និងសមាគមកសិករដែលធ្វើការនៅក្នុងតំបន់គោលដៅដូចគ្នា។ កសិករក្នុងស្រុកផ្សេងទៀតអាចចូលរួមក្នុងការវាយតម្លៃជាអ្នកសង្កេតការណ៍ដើម្បីស្វែងយល់អំពី SWSs ។

ក្នុងអំឡុងពេលនៃការវាយតម្លៃកសិដ្ឋាន អ្នកវាយតម្លៃនឹងសួរសំណួរកសិករអំពីការអនុវត្តផលិតកម្ម ការប្រើប្រាស់ទឹក និងអត្រាទាញយកទឹក ទំហំដី ហេដ្ឋារចនាសម្ព័ន្ធបច្ចុប្បន្ន និងធនធានហិរញ្ញវត្ថុដែលមានសម្រាប់ការវិនិយោគ ( សូមមើលឧបសម្ព័ន្ធទី 4 សម្រាប់សំណួរគំរូ )។ នេះក៏ជាឱកាសមួយដើម្បីណែនាំកសិករអំពីជម្រើសដែលពួកគេប្រហែលជាមិនទាន់ស្គាល់ ( សូមមើលឧបសម្ព័ន្ធទី 2 សម្រាប់បញ្ជីនៃ SWSs ) ហើយសួរពួកគេថាតើដំណោះស្រាយមួយណាដែលពួកគេអាចចាប់អារម្មណ៍។ តាមរយៈការពិភាក្សាជាមួយកសិករម្នាក់ៗ អ្នកវាយតម្លៃអាចកំណត់ថាតើវិធីសាស្ត្រគ្រប់គ្រងទឹកមួយណាគួរត្រូវបានផ្តល់អាទិភាព ដើម្បីសម្រេចបាននូវផលិតកម្មពេញមួយឆ្នាំ និងថាតើវាអាចទៅរួចផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដែរឬទេ។

### ការស្ទង់មតិទីតាំងសម្រាប់អន្តរាគមន៍រួម

សម្រាប់ដំណោះស្រាយសមូហភាពដែលការវិនិយោគសហគមន៍អាចត្រូវការជាចាំបាច់ ដូចជាអាងស្តុកទឹករួម ឬទំនប់ស្ទាក់ទឹកតូច ការវិភាគទីតាំងហ្មត់ចត់ត្រូវបានណែនាំ។ ដោយសារតែការវិភាគនេះមានធាតុផ្សំបច្ចេកទេសជាច្រើន (រួមទាំងការអង្កេតភូមិសាស្ត្ររូបវិទ្យា និងការសិក្សាសេដ្ឋកិច្ចសង្គម ) វិស្វករសំណង់ស៊ីវិលដែលមានជំនាញខាងទឹកគួរតែត្រូវបានចុះកិច្ចសន្យាដើម្បីសិក្សាអំពីលំហូរទឹក និងសមត្ថភាពស្តុកទឹកផែនទីតំបន់ និងធ្វើការរចនាបច្ចេកទេស។ បន្ទាប់មកការប៉ាន់ប្រមាណនៃតម្លៃវិនិយោគសរុបអាចត្រូវបានធ្វើឡើង។ ចំនួនអ្នកប្រើប្រាស់សក្តានុពល និងអត្ថប្រយោជន៍ក៏គួរតែត្រូវបានវាយតម្លៃ ក៏ដូចជាឆន្ទៈរបស់អ្នកប្រើប្រាស់ក្នុងការចំណាយសម្រាប់ប្រតិបត្តិការ និងការថែទាំឧបករណ៍។

# ៥.៤ ការជ្រើសរើស និងការអនុវត្តបច្ចេកវិជ្ជា SWS និង អាកាសធាតុឆ្លាតវៃ

នៅពេលដែលការសន្ទនាថ្នាក់ស្រុក និងការវាយតម្លៃកសិដ្ឋានបុគ្គលបានកើតឡើង ការប្រជុំរបស់កសិករអាចត្រូវបានធ្វើឡើងដើម្បីជ្រើសរើសអន្តរាគមន៍ SWS ត្រឹមត្រូវ និងយល់ព្រមលើការអនុវត្ត។ កសិករអាចជ្រើសរើសដំណោះស្រាយច្រើនជាងមួយពីបញ្ជី SWS ដើម្បីសម្រេចបាននូវផលិតកម្មពេញមួយឆ្នាំ ប៉ុន្តែទំហំនៃការវិនិយោគរួមគ្នាដែលផ្តល់ដោយស្ថាប័នរបស់អ្នកនឹងអាស្រ័យលើការផ្តល់មូលនិធិ។

ម្យ៉ាងទៀត កសិករដែលជ្រើសរើសដំណោះស្រាយដូចគ្នា ជួនកាលអាចត្រូវបានដាក់ជាក្រុមរួមគ្នា ដើម្បីចែករំលែកការចំណាយនៃការអន្តរាគមន៍ និងទទួលបានតម្លៃប្រសើរជាងមុន។ ឧទាហរណ៍ ប្រសិនបើកសិករមួយចំនួនដែលកសិដ្ឋាននៅជាប់គ្នាជ្រើសរើសវិនិយោគលើការអណ្តូងខួង នោះវាសមហេតុផលក្នុងការចរចាជាមួយក្រុមហ៊ុនខួងជាក្រុម ហើយខួងអណ្តូងទាំងអស់ក្នុងរយៈពេលដូចគ្នា។ នេះកាត់បន្ថយការចំណាយទាក់ទងនឹងការដឹកជញ្ជូនគ្រឿងចក្រ និងបង្កើតទំហំសេដ្ឋកិច្ចដែលអាចកាត់បន្ថយចំនួនដែលគិតថ្លៃដោយអ្នកផ្តល់សេវា។



កិច្ចប្រជុំនេះក៏ជាឱកាសមួយដើម្បីនាំកសិករ និងអ្នកផ្តល់សេវារួមគ្នា ដូច្នេះការអញ្ជើញអ្នកផ្តល់សេវា និងអ្នកលក់វាយផលិតផលមកបង្ហាញសេវាកម្ម ឬផលិតផលរបស់ពួកគេ គឺត្រូវបានផ្តល់អនុសាសន៍យ៉ាងខ្លាំង។

## បទពិសោធន៍របស់កសិករ SWS៖ អណ្តូង

«ខ្ញុំមានអាងស្តុកទឹកមួយ និងម៉ាស៊ីនបូមសូឡាតូចមួយដែលមានថ្ម ដែលមិនមានសមត្ថភាពបូមគ្រប់គ្រាន់ ហើយខូចញឹកញាប់ជាមួយអាគុយវា។ ខ្ញុំចង់បានប្រព័ន្ធបូមទឹកដោយប្រើសូឡាមួយទៀត ប៉ុន្តែខ្ញុំមិនបានស្គាល់ក្រុមហ៊ុនណាដែលមានគុណភាព និងដំណើរការល្អក្នុងការរចនាប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យទេ» កសិករ ម៉ាច ហុង រស់នៅឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ បានពន្យល់ថា។

«ជាសំណាងល្អ ក្រុមការងារគម្រោងឈេន (CHAIN) បានប្រាប់ខ្ញុំអំពីជម្រើសដំណោះស្រាយទឹកឆ្លាតវៃ (SWS) ផ្សេងទៀត ដូចជាអណ្តូងខួងដែលមានម៉ូទ័រប៉ូមទឹកដោយពន្លឺព្រះអាទិត្យ ហើយបានណែនាំខ្ញុំទៅកាន់ក្រុមហ៊ុនខួងអណ្តូង។ ខ្ញុំបានជ្រើសរើសខួងអណ្តូងអង្កត់ផ្ចិត ១២០ មីលីម៉ែត្រ និងជម្រៅ ៧៥ ម៉ែត្រ។ ខ្ញុំចំណាយត្រឹមតែ ១.០០០ ដុល្លារប៉ុណ្ណោះពីក្រុមហ៊ុនដែលបានណែនាំមក ទោះបីជាតម្លៃធម្មតាគឺ ១.២០០ ដុល្លារក៏ដោយ ដូច្នេះខ្ញុំបានសន្សំប្រាក់បន្តិចបន្តួច។»



## ការគ្រប់គ្រងធនធានទឹករួម

ទឹក គឺជាផលប្រយោជន៍រួម ដែលជាធនធានសមូហភាពដែលត្រូវការវិធីសាស្ត្ររួម ដើម្បីធានាបាននូវលទ្ធភាពទទួលបានដោយសមធម៌ និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព។ បទប្បញ្ញត្តិ ឬច្បាប់ត្រូវមាន ដើម្បីជៀសវាងការទាញយកហួសដែន និងកាត់បន្ថយហានិភ័យ។ ហេដ្ឋារចនាសម្ព័ន្ធសមូហភាពធំៗ ដូចជាអាងស្តុកទឹកសហគមន៍ និងទំនប់ស្នាក់ទឹកតូច អាចជាដំណោះស្រាយដ៏ល្អសម្រាប់ការស្តុកទឹក។ វាអាចត្រូវបានប្រើដោយសហគមន៍សម្រាប់ប្រព័ន្ធធារាសាស្ត្រកសិកម្មដោយបង្កើតកិច្ចព្រមព្រៀងក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។ វាគួរតែរួមបញ្ចូលច្បាប់ស្តីពីបរិមាណទាញយកទឹក ការការពារប្រភពទឹក និងការបង់ប្រាក់ថែទាំ។ ពេលខ្លះមូលនិធិអភិវឌ្ឍន៍ឃុំ ឬស្រុកអាចប្រើប្រាស់សម្រាប់ការដំឡើងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ប៉ុន្តែការចំណាយលើការថែទាំ និងប្រតិបត្តិការជាធម្មតាត្រូវបានផ្តល់ហិរញ្ញប្បទានដោយអ្នកប្រើប្រាស់។ នៅក្នុងគម្រោងប្រព័ន្ធធារាសាស្ត្រជាច្រើន សមាគមអ្នកប្រើប្រាស់ទឹកត្រូវបានបង្កើតឡើងដើម្បីទូទាត់ថ្លៃចំណាយទាំងនេះ។ ការងាររៀបចំសហគមន៍ជាច្រើនត្រូវធ្វើមុនពេលវិនិយោគ ដើម្បីធានាបាននូវដំណើរការល្អនៃគម្រោងបែបនេះ។

ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសមូហភាពច្រើនតែធំពេកសម្រាប់កសិករដើម្បីទទួលរ៉ាប់រង។ គម្រោងឈេន (CHAIN) និងកសិករដែលពាក់ព័ន្ធបានទៅជួបមន្ទីរធនធានទឹក និងឧតុនិយម (PDWRAMs) និងរដ្ឋាភិបាលស្រុកដើម្បីស្វែងរកសហមូលនិធិ។ ជាលទ្ធផល ដំណោះស្រាយសមូហភាពចំនួនប្រាំត្រូវបានអនុវត្ត៖

(១) ប្រឡាយសម្រាប់តភ្ជាប់អាងស្តុកទឹករួមជាមួយនឹងប្រឡាយធម្មជាតិដើម្បីផ្គត់ផ្គង់ទឹកពេញមួយឆ្នាំ (២) ការពង្រីក និងជីកអោយជ្រៅអាងស្តុកទឹករួម (៣) ការដំឡើងបំពង់បញ្ជូនទឹកទៅកាន់អាងស្តុកទឹក និង (៤) សាងសង់ទំនប់ស្នាក់ទឹកតូចៗដើម្បីបង្កើតអាងស្តុកទឹក។ នៅក្នុងការសន្ទនាថ្នាក់ស្រុក ការវិនិយោគទាំងនេះត្រូវបានផ្តល់អាទិភាព និងនៅពេលក្រោយត្រូវបានបញ្ចូលទៅក្នុងថវិកាអភិវឌ្ឍន៍ឃុំ និងអនុវត្តជាបន្តបន្ទាប់។



## បទពិសោធន៍កសិករ SWS៖ ការសាងសង់ទំនប់ស្ទាក់ទឹក និងអាងស្តុកទឹកសហគមន៍

សហគមន៍ជនជាតិដើមភាគតិចព្នៅ នៅឃុំកាតូត ខេត្តស្ទឹងត្រែង មិនមានទឹកគ្រប់គ្រាន់នៅរដូវប្រាំង។ អណ្តូងខួងមួយបានផ្តល់ទឹកដែលមានជាតិដែកច្រើនពេក។ នៅក្នុងកិច្ចសន្ទនាថ្នាក់ស្រុក សហគមន៍បានកំណត់ខ្សែទឹកដែលអាចមានទំនប់តូចមួយដើម្បីបង្កើតអាងស្តុកទឹកតូចមួយ។ ដោយមានវិស្វករក្នុងស្រុក និងការគាំទ្រពីអភិបាលខេត្ត ការចុះអង្កេត និងរៀបចំទីតាំងត្រូវបានធ្វើឡើង។ គម្រោងឈេន (CHAIN) បានសហការវិនិយោគជាប្រេងឥន្ធនៈសម្រាប់ការកាយដី ហើយរដ្ឋាភិបាលក្នុងតំបន់បានផ្តល់ហិរញ្ញប្បទានជាម៉ាស៊ីន និងការសាងសង់ទំនប់ខ្នាតតូចនេះ។ លោក សុវណ្ណ ពិសិដ្ឋ អភិបាលស្រុកបានមានប្រសាសន៍ថា គម្រោងសាងសង់ទំនប់ស្ទាក់ទឹកខ្នាតតូចនេះ បង្ហាញពីលទ្ធផលល្អដែលអាចធ្វើទៅបានពីកិច្ចសហប្រតិបត្តិការរវាងអង្គការដៃគូ និងរាជរដ្ឋាភិបាល។ វាឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនក្នុងមូលដ្ឋាន សម្រាប់ទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃក្នុងគ្រួសារ និងសម្រាប់ស្រោចស្រពដំណាំបន្លែ។





## ផ្ទះសំណាញ់

ទោះបីជាការទទួលបានទឹកក្នុងរដូវប្រាំងត្រូវបានដោះស្រាយក៏ដោយ ក៏កសិករនៅតែប្រឈមនឹងបញ្ហាដោយសារភ្លៀងធ្លាក់ខ្លាំងនៅរដូវវស្សា ដែលអាចបង្កបញ្ហាដល់បន្លែ ជាពិសេសបន្លែស្លឹក។ ផ្ទះសំណាញ់អាចរកបានតាមប្រភេទផ្សេងៗគ្នាក្នុងតម្លៃផ្សេងៗគ្នា។ ពួកវាអាចការពារការខូចខាតពីទឹកភ្លៀងដោយគ្របដំណាំជាមួយនឹងដំបូលប្លាស្ទិកនិងពីសត្វល្អិតដោយសំណាញ់ជុំវិញ។ ទោះជាយ៉ាងណាក៏ដោយ ការដំឡើងផ្ទះសំណាញ់ត្រូវតែគិតគូរពីកត្តាផ្សេងៗ ដូចជាការឡើងកំដៅខ្លាំងពេក និងការខូចខាតដែលអាចកើតមាន ឬការផ្លាស់ទីដោយសារខ្យល់ និងព្យុះ។ កសិករត្រូវតាមដានផ្ទះសំណាញ់របស់ពួកគេជាបន្តបន្ទាប់។ ឧទាហរណ៍ ប្រសិនបើសីតុណ្ហភាពក្នុងផ្ទះសំណាញ់ឡើងខ្ពស់ពេក ពួកគេត្រូវធ្វើការកែសម្រួលបណ្តោះអាសន្ន ដូចជាការបើករន្ធខ្យល់ក្នុងដំបូលប្លាស្ទិកមូរឡើង ដាក់សំណាញ់ខៀវឬខ្មៅជាម្លប់ ឬបើកកង្ហារផ្សេងដើម្បីបញ្ចេញកម្តៅ។



### បទពិសោធន៍កសិករ SWS៖ ផ្ទះសំណាញ់



អ្នកស្រី ប្លោក សិទ្ធ កសិកររស់នៅខេត្តក្រចេះ បានសម្តែងការពេញចិត្តចំពោះសេវាកម្មថែទាំផ្ទះសំណាញ់ ដែលអ្នកស្រីបានចុះកិច្ចសន្យាសហការវិនិយោគ និងសម្របសម្រួលជាមួយគម្រោង CHAIN។ អ្នកស្រី សិទ្ធ បានរៀបរាប់ថា «ខ្ញុំបានចំណាយប្រាក់ ៣០០ ដុល្លារ ដើម្បីជំនួសផ្ទះសំណាញ់ចាស់របស់ខ្ញុំជាមួយនឹងផ្លាស្ទិក UV និង USD ២.០០០ សម្រាប់ការដំឡើងផ្ទះសំណាញ់ថ្មីមួយទៀត។ បន្ទាប់ពីការជុសជុលនេះរួច ឥឡូវនេះខ្ញុំអាចដាំបន្លែបានជាប់លាប់។ ដោយសារខ្ញុំអាចដាំបានពេញមួយឆ្នាំ ខ្ញុំទទួលបានតម្លៃខ្ពស់ក្នុងរដូវវស្សា។ ឥឡូវនេះ ខ្ញុំ និងស្វាមីកំពុងគិតក្នុងការដំឡើងផ្ទះសំណាញ់ពីរបន្ថែមទៀតសម្រាប់ការផលិតបន្លែខ្នាតធំ និងរកប្រាក់ចំណូលបន្ថែមទៀត»។

# ៥.៥ ការបណ្តុះបណ្តាលគ្រូបង្គោល/ការគាំទ្រ SME

ការបណ្តុះបណ្តាលគ្រូបង្គោល (ToT) មានគោលបំណងសម្រាប់មន្ត្រីផ្នែកផ្សព្វផ្សាយរបស់រដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាលឃុំ/សង្កាត់ និងបុគ្គលិកធ្វើការនៅទីវាលមកពីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀត។ តាមរយៈការទស្សនាកសិដ្ឋាន និងចម្ការបង្ហាញ វគ្គបណ្តុះបណ្តាលនេះជួយសិក្ខាកាមឱ្យយល់អំពីគោលគំនិតដែលនៅពីក្រោយ SWS និងការអនុវត្តដ៏ឆ្លាតវៃផ្សេងៗពីអាកាសធាតុ។

ចាប់ផ្តើមដោយកំណត់គោលបំណងជាក់លាក់ និងវិធីសាស្រ្តបណ្តុះបណ្តាល រៀបចំបញ្ជីអ្នកចូលរួម និងការប៉ាន់ប្រមាណតម្លៃនៃការបណ្តុះបណ្តាល បន្ទាប់មកគូរផែនការមេរៀន និងបញ្ជីសម្ភារៈដែលត្រូវការ។ កម្មវិធីសិក្សាគួរគ្របដណ្តប់លើគោលការណ៍ជាមូលដ្ឋាន និងការអនុវត្តរបស់ដំណោះស្រាយទឹកឆ្លាតវៃ (SWSs) និង អាកាសធាតុឆ្លាតវៃសម្រាប់វិស័យសាកវប្បកម្ម (Climate-Smart Horticulture)។ វាគួរតែរួមបញ្ចូលលំហាត់ដើម្បីឱ្យអ្នកចូលរួមអាចគណនាតម្រូវការទឹក (ផ្អែកលើផ្ទៃដីដំណាំ) នៅក្នុងករណីសិក្សាជាក់លាក់មួយ។ ការរៀនក្នុងថ្នាក់គួរលើកយកប្រធានបទសំខាន់ៗចំនួនបួន៖ ការគ្រប់គ្រងជីជាតិ ការគ្រប់គ្រងធនធានទឹក អន្តរាគមន៍ SWS ដែលសមស្រប នឹងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ។

បន្ទាប់ពីវគ្គរៀនក្នុងថ្នាក់មួយ ឬច្រើនមេរៀនហើយ វគ្គបណ្តុះបណ្តាលគួរបន្តជាមួយការទស្សនៈកិច្ចនៅទីតាំងដែលសិក្ខាកាមអាចសង្កេតមើលការអនុវត្ត SWSs និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ និងមានឱកាសនិយាយដោយផ្ទាល់ជាមួយកសិករ និងអ្នកបច្ចេកទេស។ លើសពីនេះ ការពិភាក្សាជាក្រុមតូចៗអាចធ្វើឡើងដោយមានការចូលរួមពីមេឃុំ ឬអភិបាលស្រុក និងមន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) ដើម្បីស្វែងយល់ពីរបៀបបញ្ចូលការវិនិយោគ SWS នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## ព័ត៌មានជំនួយ

សម្ភារៈសិក្សាគ្រូបង្គោល (ToT) គឺជាការរួមបញ្ចូលគ្នានៃកសិកម្ម និងធារាសាស្រ្ត។ ដូច្នេះ ប្រសិនបើអ្នកសម្របសម្រួល គឺជាអ្នកជំនាញខាងកសិកម្ម វាជាការល្អបំផុតដើម្បីពិគ្រោះជាមួយវិស្វករទឹកនៅពេលរៀបចំការគណនាតម្រូវការទឹក ទំហំទុយោ សមត្ថភាពលំហូរទឹក សមត្ថភាពម៉ាស៊ីនភ្លើង និងសមត្ថភាពបូមទឹក។

### ការបណ្តុះបណ្តាល SME

ក្រុមការងារគម្រោងឈេន (CHAIN) បានរកឃើញថាក្រុមហ៊ុនជាច្រើនដែលលក់សម្ភារៈ និងបច្ចេកវិជ្ជា SWS ចង់ណែនាំដល់កសិករ ប៉ុន្តែខ្វះចំណេះដឹងផ្នែកបច្ចេកទេស។ ការបណ្តុះបណ្តាលមួយចំនួនលើទិដ្ឋភាពបច្ចេកទេសនៃ SWSs បានជួយ។ សំខាន់ជាងនេះទៅទៀត ក្រុមហ៊ុនចង់ពង្រីកការផ្តល់ជូនទីផ្សាររបស់ពួកគេ និងរៀនពីរបៀបបង្កើតផែនការអាជីវកម្មដើម្បីទទួលបានប្រាក់កម្ចី និងវិធីសាស្រ្តទីផ្សារអ្វីដែលត្រូវប្រើ។ គម្រោងឈេន (CHAIN) បានជួយអាជីវកម្មទាំងនេះមួយចំនួនឱ្យពង្រីកតាមរយៈការវិនិយោគរួមគ្នា។ ជំនួយការបណ្តុះបណ្តាលអាជីវកម្មដល់សហគ្រាសធុនតូច និងមធ្យមត្រូវបានពិពណ៌នាយ៉ាងលម្អិតនៅក្នុងសៀវភៅមគ្គុទេសក៍របស់គម្រោងឈេន (CHAIN HTG) មួយផ្សេងទៀតដែលមានចំណងជើងថា កម្មវិធីបង្កើនល្បឿនអាជីវកម្មជនបទ (Rural Business Accelerator)។

## ការចាប់ផ្ដើមអាជីវកម្មដំឡើងផ្ទះសំណាញ់

លោក ប៊ិន ហុងលី ជាកសិករវ័យក្មេងរស់នៅខេត្តក្រចេះ ចង់មានផ្ទះសំណាញ់ ប៉ុន្តែត្រូវបានផ្អាកដោយការចំណាយខ្ពស់ពេក។ គាត់បានឃើញផ្ទះសំណាញ់មួយចំនួនដែលធ្វើពីឬស្សី ហើយបានស្រាវជ្រាវរកតាមវីដេអូយូធូបពីរបៀបសាងសង់វា។ គាត់បានសាងសង់ផ្ទះសំណាញ់តូចៗចំនួន ២ ហើយបានក្លាយជាបទពិសោធន៍ក្នុងការដំឡើងផ្ទះសំណាញ់ផ្ទាល់ខ្លួនរបស់គាត់។ លោកបានឮការត្អូញត្អែរជាច្រើនពីកសិករអំពីការខូចខាតដំបូលផ្លាស្ទិកនៃសំណាញ់របស់ពួកគេ និងការលំបាកក្នុងការជួសជុលពួកគេ។ បន្ទាប់ពីការសន្ទនាជាមួយបុគ្គលិកគម្រោងឈេន (CHAIN) គាត់បានស្នើឱ្យចាប់ផ្ដើមសេវាកម្មជួសជុល និងដំឡើងផ្ទះសំណាញ់ ដោយផ្តល់ជូននូវបង្គោលដែកថ្មីដើម្បីទប់ផ្ទះសំណាញ់ក្នុងតម្លៃមួយភាគបីនៃក្រុមហ៊ុនដែលបានបង្កើតឡើង។ ដោយមានការគាំទ្រផ្នែកបណ្តុះបណ្តាលអាជីវកម្មពីគម្រោងឈេន (CHAIN) និងការសហការវិនិយោគលើដើមទុនធ្វើការសម្រាប់សម្ភារៈ និងឧបករណ៍ កសិករវ័យក្មេងរូបនេះបានចាប់ផ្ដើមអាជីវកម្មផ្ទាល់ខ្លួនរបស់គាត់។ ជាលទ្ធផល ឥឡូវនេះ កសិករនៅខេត្តក្រចេះ មានលទ្ធភាពប្រើប្រាស់ផ្ទះសំណាញ់សាងសង់ក្នុងស្រុកដែលមានតម្លៃទាប។





### អ្នកផ្ដល់សេវា៖
### សេវាជួសជុលបន្ទះសូឡា - SOGE

ក្រុមហ៊ុន Solar Green Energy Cambodia – SOGE គឺជាក្រុមហ៊ុនសូឡាដែលផ្តល់នូវដំណោះស្រាយទឹកស្អាតវៃដែលមានគុណភាពខ្ពស់ដោយប្រើប្រាស់សូឡា។ គំរូបែបផែនផលិតផលរបស់ពួកគេជាមួយនឹងការតាមដានពន្លឺព្រះអាទិត្យដោយស្វ័យ ប្រវត្តិបង្វិលបន្ទះសូឡាចំនួន ៦ដងក្នុងមួយថ្ងៃ និងប្រព័ន្ធបូមទឹកអាចត្រូវបានត្រួតពិនិត្យពីចម្ងាយ។ SOGE ដំឡើង ថែទាំ និងផ្តល់ការធានារយៈពេល ៥ ឆ្នាំ។ អាយុកាលប្រើប្រាស់រហូតដល់ ១៥ ឆ្នាំជាមួយនឹងការថែទាំត្រឹមត្រូវ។ ដើម្បីផ្តល់សេវាកម្មកាន់តែប្រសើរដល់អតិថិជនរបស់ពួកគេដែលជារឿយៗមានទីតាំងនៅឆ្ងាយពីការិយាល័យនៅទីក្រុងភ្នំពេញ ក្រុមហ៊ុនបានសម្រេចចិត្តស្វែងរកអ្នកចែកចាយក្នុងស្រុក ដែលអាចផ្តល់សេវាកម្មដំឡើង និងជួសជុលផងដែរ។ រួមគ្នាជាមួយគម្រោងឈេន (CHAIN) ក្រុមហ៊ុនបានហៅកសិករក្នុងស្រុក និងអ្នកបច្ចេកទេសក្នុងស្រុក ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលដើម្បីក្លាយជាអ្នកជួសជុល និងដំឡើង SOGE ដែលត្រូវបានទទួលស្គាល់។ វគ្គបណ្តុះបណ្តាលត្រូវបានផ្តល់ជូនតាមអ៊ីនធឺណិតតាមរយៈ Zoom និងផ្ទាល់សម្រាប់ការអនុវត្តដំឡើងផ្ទាល់។ ការចំណាយសម្រាប់អ្នកចូលរួមម្នាក់ៗគឺ ៥0 ដុល្លារអាមេរិកដែលត្រូវបង់ជាមុន។ ជាលទ្ធផល កសិករជាង ២00 នាក់បានសម្ដែងចំណាប់អារម្មណ៍ចង់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ប៉ុន្តែមានតែ ៤0 នាក់ប៉ុណ្ណោះដែលត្រូវបានអនុញ្ញាត។ ក្នុងចំណោម ៣៥ នាក់ដែលបានបញ្ចប់វគ្គនេះ មាន ២0 នាក់ត្រូវបានជ្រើសរើសឱ្យបង្កើតអាជីវកម្មខ្នាតតូចដោយមានការគាំទ្រឧបករណ៍មួយចំនួនដែលជាសហវិនិយោគ។

# ៥.៦ ការចែករំលែកចំណេះដឹងតាមរយៈវេទិកាឌីជីថល

នៅពេលដែលកសិករបានអនុវត្ត SWS ឬបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ (ឧ. ខ្លួងអណ្តូង ការដំឡើងម៉ាស៊ីនបូមទឹកប្រើសូឡា ឬផ្ទះសំណាញ់ ឬប្រើចំបើងជាជីសរីរាង្គ) ពួកគេនឹងសង្ឃឹមថានឹងសម្រេចបាននូវគោលដៅដែលចង់បាន៖ ផលិតកម្មពេញមួយឆ្នាំ កើនឡើងផលិតភាព ការផ្គត់ផ្គង់ទៀងទាត់ដល់អ្នកទិញ និងឱកាសទីផ្សារដែលប្រសើរឡើង។ ទោះជាយ៉ាងណាក៏ដោយ មានតែអ្នកជិតខាងរបស់ពួកគេប៉ុណ្ណោះដែលអាចដឹងពីរឿងរ៉ាវជោគជ័យទាំងនេះ និងរបៀបដែលពួកគេសម្រេចបាន ខណៈដែលកសិករផ្សេងទៀតនៅក្នុងស្រុក ឬខេត្តទំនងជាមិនបានឃើញ SWSs ទាំងនេះនៅក្នុងសកម្មភាពនោះទេ។ ដើម្បីឱ្យកសិករផ្សេងទៀត បុគ្គលិកនៅទីវាល និងអ្នកផ្សព្វផ្សាយអាចទទួលបានចំណេះដឹងដែលបង្កើតឡើងដោយកសិករដែលអនុវត្ត SWSs ដោយជោគជ័យ គម្រោងឈេនបានផ្សព្វផ្សាយការចែករំលែកកសិករតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមតាមជំហានសាមញ្ញចំនួនបី៖



**ប្រព័ន្ធផ្សព្វផ្សាយសង្គមតាមជំហានសាមញ្ញចំនួនបី៖**

**១. លើកទឹកចិត្តឱ្យមានទម្លាប់ក្នុងការចែករំលែកការអនុវត្តស្រែចម្ការល្អក្នុងចំណោមកសិករ។ បណ្តុះបណ្តាលកសិករឱ្យប្រើស្មាតហ្វូនរបស់ពួកគេដើម្បីថតវីដេអូអំពីបច្ចេកទេស និងលទ្ធផលកសិកម្មរបស់ពួកគេ។**

**២. បណ្តុះបណ្តាលកសិករឱ្យប្រើស្មាតហ្វូនរបស់ពួកគេដើម្បីថតវីដេអូអំពីបច្ចេកទេស និងលទ្ធផលកសិកម្មរបស់ពួកគេ។**

**៣. ប្រើវេទិកាឌីជីថល ឬបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីចែករំលែកវីដេអូសិក្សា ទិន្នន័យទីផ្សារ និងព័ត៌មានមានប្រយោជន៍ផ្សេងទៀតទាក់ទងនឹងការធ្វើកសិកម្ម។**

កសិករវ័យក្មេងភាគច្រើនបានប្រើប្រាស់ស្មាតហ្វូនសម្រាប់ការទំនាក់ទំនង និងប្រើប្រាស់ការកម្សាន្តតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមដ៏ពេញនិយមដូចជា Facebook និង YouTube ។ កម្មវិធីផ្ញើសារដូចជា Messenger ឬ Telegram គឺជាវេទិកាដ៏ល្អសម្រាប់កសិករដើម្បីបង្កើតក្រុមជជែកដែលមានគំនិតដូចគ្នា ទំនាក់ទំនងគ្នាទៅវិញទៅមក និងចែករំលែកព័ត៌មានទាក់ទងនឹងការធ្វើកសិកម្ម ដូចជា ប្រតិទិនកសិកម្ម ឱកាសទីផ្សារ ការអនុវត្តកសិកម្មល្អ ផលិតផល និងសេវាកម្ម SWS ការគ្រប់គ្រងសត្វល្អិតជាដើម។

ស្មាតហ្វូនភាគច្រើនមានមុខងារថតរូប និងកាត់តវីដេអូកម្រិតខ្ពស់ជាមួយនឹងជំនួយកម្មវិធីពាក់ព័ន្ធ ប៉ុន្តែកសិករជាច្រើនមិនដឹងពីរបៀបប្រើប្រាស់មុខងារទាំងនេះឱ្យមានប្រសិទ្ធភាពនោះទេ។ សូមមើលសៀវភៅមគ្គុទេសក៍របស់គម្រោងឈេនដែលមានចំណងជើងថា វីដេអូអ្នកសិករសម្រាប់ការផ្សព្វផ្សាយតាមឌីជីថល (Farmer Videos for Digital Extension) សម្រាប់ការណែនាំអំពីរបៀបបណ្តុះបណ្តាលកសិករក្នុងវីដេអូក្រាហ្វិច និងរបៀបរៀបចំការប្រកួតវីដេអូដើម្បីលើកទឹកចិត្តដល់ការបង្កើត និងការផ្លាស់ប្តូរវីដេអូកសិករ។

## ព័ត៌មានជំនួយ

- បង្កើតក្រុមចែករំលែកចំណេះដឹងដោយប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមដែលកសិករស្គាល់ ឬប្រើរួចមកហើយ ដូចជា Facebook និង Telegram ។
- នៅពេលណែនាំកម្មវិធីទូរស័ព្ទសម្រាប់ការកែសម្រួលវីដេអូ សូមប្រាកដថាវាមានទាំងក្នុងទម្រង់ Android និង iOS។ ជ្រើសរើសកម្មវិធីសាមញ្ញដែលមិនពាក់ព័ន្ធនឹងជំហានច្រើនពេកក្នុងពេលប្រើប្រាស់។

### បទពិសោធន៍ SWS របស់កសិករ៖
### គម្របដី

លោក អ៊ឹម ណៃស្រ៊ាង កសិករមកពីឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ បាននិយាយថា «ខ្ញុំបានរៀនពីមន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) អំពីគ្របរង និងប្រើចំបើងលើរងបន្លែរបស់ខ្ញុំ។ គម្របរក្សាដីបានច្រើន ដូច្នេះខ្ញុំអាចប្រើទឹកតិច។ ខ្ញុំទទួលបានទិន្នផលស្ពៃចង្កឹះខ្ពស់ ហើយឥឡូវនេះអាចដាំបានច្រើនជាងពីរដងដោយប្រើបរិមាណទឹកដូចគ្នានៅក្នុងស្រះរបស់ខ្ញុំ!»



# ៦. សន្និដ្ឋាន

ការប្រែប្រួលអាកាសធាតុនាពេលអនាគតនឹងតម្រូវឱ្យមានការវិនិយោគនៅក្នុង SWSs និងបច្ចេកវិជ្ជាធន់នឹងអាកាសធាតុផ្សេងទៀត។ វិធីសាស្រ្តដែលអាចបត់បែនបានជាមួយនឹងបញ្ជីជម្រើសអាចឱ្យកសិករជ្រើសរើសដំណោះស្រាយសមស្របបំផុត មិនថាសម្រាប់កសិដ្ឋានបុគ្គលផ្ទាល់ ឬហេដ្ឋារចនាសម្ព័ន្ធសមូហភាព។ ដំណើរការដែលមានការចូលរួមពីរដ្ឋាភិបាល ធុរកិច្ច និងក្រុមកសិករនឹងបង្កើតសមត្ថភាព និងបណ្តាញក្នុងស្រុក ដើម្បីឱ្យដំណោះស្រាយមាននិរន្តរភាព និងបម្រើជាកន្លែងបង្ហាញសម្រាប់អ្នកដទៃដើម្បីរៀនសូត្របាន។ ការកំណត់ចំណាប់អារម្មណ៍ និងតម្រូវការរបស់កសិករក្នុងការវិនិយោគលើដំណោះស្រាយទាំងនេះ និងការភ្ជាប់ពួកគាត់ជាមួយអ្នកផ្គត់ផ្គង់ និងអ្នកផ្តល់សេវាដែលផ្តល់ជូន SWSs ជាអាជីវកម្ម នឹងពង្រឹងប្រព័ន្ធទីផ្សារ ដូច្នេះវាអាចប្រឈមមុខនឹងបញ្ហានាពេលអនាគត។ ការលើកកម្ពស់ការវិនិយោគដ៏ឆ្លាតវៃនឹងអាកាសធាតុក្នុងស្រុកនឹងបង្កើតផលិតភាពខ្ពស់ ប្រាក់ចំណេញ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់កសិករជាច្រើន។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

## ប្រធានបទសម្រាប់ការវាយតម្លៃបឋម

**ប្រធានបទដែលត្រូវគ្របដណ្តប់នៅក្នុងការវាយតម្លៃ**

### ប្រព័ន្ធកសិកម្មសំខាន់ៗ៖

- សំណាំជាក់លាក់
- បញ្ហាផលិតកម្មដំណាំ
- ទីផ្សារ និងសក្តានុពលផលចំណេញនៃដំណាំ

### ទឹក៖

- អាងទឹកសំខាន់ៗ ដូចជា ទន្លេ បឹង អាងស្តុកទឹក
- តំបន់ការពារប្រភពទឹក (ច្រាំងទន្លេ អាងស្តុកទឹក ភ្នំ) ព្រៃ (រួមបញ្ចូលផែនទីប្រសិនបើមាន)
- ការយកទឹក ការស្តុកទុក ការដឹកជញ្ជូន និងវិធីប្រើប្រាស់នៅក្នុងស្រុក - បុគ្គល និងសមូហភាព
- ផ្ទៃដីស្រោចស្រពសរុប និងវិធីសាស្ត្រ
- កម្រិតទឹកក្រោមដី និងការប្រែប្រួលរដូវប្រាំង
- គុណភាពទឹកក្រោមដី

### បញ្ហាប្រឈមអាកាសធាតុសំខាន់ៗ៖

- លទ្ធភាពនៃទឹកជំនន់ គ្រោះរាំងស្ងួត ការឡើងកំដៅ ការខូចខាតដោយទឹកភ្លៀង ការខូចខាតដោយខ្យល់ សត្វល្អិត និងជំងឺ
- ការប្រែប្រួលអាកាសធាតុសង្កេតឃើញដោយកសិករ
- ដំណោះស្រាយបានអនុវត្តរួចហើយនៅស្រុក

### សក្តានុពលសម្រាប់អន្តរាគមន៍ SWS៖

- កសិដ្ឋាន/ដីដែលបានកំណត់អត្តសញ្ញាណដែលអាចបម្រើជាកន្លែងបង្ហាញដំណោះស្រាយដែលបានអនុវត្តរួចហើយ
- បានសង្កេតឃើញកំហុសទូទៅក្នុងដំណោះស្រាយ
- បច្ចេកវិជ្ជា/ដំណោះស្រាយមិនទាន់អនុវត្តនៅក្នុងស្រុក
- សក្តានុពលសម្រាប់ការកែលម្អដំណោះស្រាយរដូវប្រាំង ដំណោះស្រាយរដូវវស្សា
- បង្ហាញពីចំណាប់អារម្មណ៍ និងការលើកទឹកចិត្តរបស់អាជ្ញាធរ
- ការផ្តល់ហិរញ្ញប្បទានសំខាន់ៗនៅក្នុងស្រុក (មូលនិធិរបស់រដ្ឋាភិបាល មូលនិធិគម្រោង គ្រឹះស្ថានហិរញ្ញវត្ថុ ឆន្ទៈរបស់កសិករក្នុងការទូទាត់ ផលិតផលដែលអាចលក់បាន និងប្រាក់ចំណេញកើនឡើង)

# ឧបសម្ព័ន្ធ២

## បញ្ជី SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

### បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| | ដំណោះស្រាយ/បច្ចេកវិជ្ជា | មុខងារចម្បង | បុគ្គល | សមូហភាព |
|---|---|---|---|---|
| | | **លទ្ធភាពទទួលបានទឹក / ការអភិវឌ្ឍន៍ប្រភពទឹក** | | |
| 1 | អណ្តូង | ការទទួលបានប្រភពទឹកក្រោមដីដែលអាចទុកចិត្តបាន។ | X | |
| 2 | ទំនប់ស្ទាក់ទឹក | បង្កើតរបាំងនៅក្នុងអូរធម្មជាតិដើម្បីតម្លើងកម្រិតទឹក ហើយដូច្នេះអាចបូមបាន | X | X |
| 3 | ស្រះទឹកកសិដ្ឋាន | រក្សាទុកទឹកនៅក្នុងកសិដ្ឋាន | X | |
| 4 | ទ្រនាប់ស្រះ | ជៀសវាងការបាត់បង់ទឹកពីស្រះកសិដ្ឋាន | X | |
| 5 | ធុងទឹកខ្ពស់ | ស្តុកទឹកសម្រាប់ប្រព័ន្ធធារាសាស្ត្រផ្គត់ផ្គង់ដោយទំនាញ | X | |
| 6 | ការការពារទឹក | ការពារអណ្តូង ឬប្រភពទឹកដែលមានគម្របព្រៃ | | X |
| | | **ការយកទឹក / បញ្ចេញទឹក** | | |
| 7 | សូឡាបូមទឹក | ការបញ្ចេញទឹក និងបូមទឹកដោយប្រើសូឡា; វាអាចត្រូវបានធ្វើជាមួយនឹងកម្មវិធីតាមដានពន្លឺព្រះអាទិត្យដើម្បីបង្កើនបរិមាណថាមពល | X | |
| 8 | ម៉ាស៊ីនបូមទឹកប្រើសាំង | បញ្ចេញទឹក និងបូមទឹកក្នុងតម្លៃដើមទុនទាប | X | |
| 9 | ម៉ាស៊ីនបូមទឹកប្រើប្រេងម៉ាស៊ូត | បញ្ចេញទឹកសម្រាប់ដីទំហំធំ និងបរិមាណទឹកកាន់តែច្រើន | X | |
| | | **ការប្រើប្រាស់ទឹក និងការរក្សាសំណើមដី / អាកាសធាតុតូច** | | |
| 10 | កៅស៊ូគ្របរង | ការពារពីសំណឹកដី កាត់បន្ថយការហួតដី គ្រប់គ្រងសីតុណ្ហភាពដី និងទប់ស្កាត់ស្មៅ | X | |
| 11 | ចំបើង/ ជីសរីរាង្គ | ការពារការហូរច្រោះដី កាត់បន្ថយការបាត់បង់សំណើមដី គ្រប់គ្រងសីតុណ្ហភាពដី និងទប់ស្កាត់ស្មៅ | X | |
| 12 | គម្របដំណាំ | ការពារប្រឆាំងនឹងសំណឹកដី កាត់បន្ថយការហួតដី និងបង្កើតសារធាតុសរីរាង្គបន្ថែម | X | |
| 13 | អាងខ្វាតតូច | ប្រមូលការហូរចេញពីផ្ទៃខាងលើ និងជាប្រព័ន្ធធារាសាស្ត្រដ៏មានប្រសិទ្ធភាពជុំវិញដំណាំឈើហូបផ្លែ | X | |
| 14 | ការដាំលើរង | បើកដំណើរការប្រព័ន្ធធារាសាស្ត្រដែលបានគ្រប់គ្រង និងការបញ្ចេញឬសល្អនៅក្នុងតំបន់ដែលងាយនឹងមានការជ្រាបទឹក និងកាត់បន្ថយការហូរច្រោះ | X | |
| 15 | កម្រិតដីច្បាស់លាស់ | បាចទឹកស្មើលើវាល | X | |

| | | | | |
|---|---|---|---|---|
| 16 | ជីកំប៉ុសដី និងជីវខស្ម័ន | បង្កើនសមត្ថភាពរក្សាទឹក និងសារធាតុចិញ្ចឹមរបស់ដី | X | |
| 17 | ប្រព័ន្ធធារាសាស្ត្រ | ប្រព័ន្ធធារាសាស្ត្រច្បាស់លាស់ ជីជាតិ | X | |
| 18 | ម៉ាស៊ីនបាញ់ទឹកខ្នាតតូច | សាចទឹកនៅលើផ្ទៃ ការស្រោចស្រពច្បាស់លាស់ សូម្បីតែការចែកចាយទឹក។ | X | |
| 19 | បំពង់បាញ់ទឹកភ្លៀង | បំពង់ធារាសាស្ត្រដែលមានរន្ធតូចៗ ត្រូវបានគេស្គាល់ថាជាបំពង់បាញ់ទឹកភ្លៀង ដើម្បីបង្កើតជាដំណក់ទឹកតូចៗ ជាពិសេសមានប្រយោជន៍សម្រាប់បន្លែស្លឹក។ | X | |
| 20 | ផ្ទះសំណាញ់ | ការការពារពីភ្លៀងធ្លាក់ខ្លាំង កាត់បន្ថយការបាត់បង់ការហួត គ្រប់គ្រងសីតុណ្ហភាព និងសំណើមខ្យល់ | X | |
| 21 | ទុយោ PVC | បញ្ជូនទឹកពីចំណុច A ដល់ចំណុច B ពេលដែលជៀសវាងការបាត់បង់ទឹក អាចត្រូវបានប្រើលើកម្ពស់ខុសគ្នា អាចកប់ក្នុងដី | X | |
| 22 | ទុយោបត់ | បញ្ជូនទឹកពីចំណុច A ដល់ចំណុច B ពេលដែលជៀសវាងការបាត់បង់ទឹក អាចត្រូវបានប្រើលើកម្ពស់ខុសគ្នា | X | |
| 23 | ឧបករណ៍ចាប់សញ្ញាសំណើម | វាស់សំណើមដីសម្រាប់ការផ្គត់ផ្គង់ទឹកដែលមានភាពជាក់លាក់ខ្ពស់ ធានាការស្រោចស្រពនៅពេលវេលាត្រឹមត្រូវ និងក្នុងបរិមាណត្រឹមត្រូវ | X | |
| **ការគ្រប់គ្រងធនធានទឹករួម** | | | | |
| 24 | អាងស្តុកទឹករួម | រក្សាទុកទឹកលើផ្ទៃដីក្នុងបរិមាណច្រើនសម្រាប់ប្រើប្រាស់ក្នុងសហគមន៍ | | X |
| 25 | ប្រឡាយផ្គត់ផ្គង់ទឹកជាមួយទ្វារទឹក។ | បញ្ជូនបរិមាណទឹកច្រើនពីប្រភពអចិន្ត្រៃយ៍ទៅកាន់អាងស្តុកទឹក។ | | X |

# បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| ល.រ ១ | អណ្តូង |
|---|---|
| **ប្រភេទ** | **ការអភិវឌ្ឍន៍ធនធានទឹក** |
| ការពិពណ៌នាខ្លី | រណ្តៅត្រូវបានខួងដោយឧបករណ៍ខួងចូលទៅក្នុងជម្រៅ ៣០-២០០ ម៉ែត្រ ដើម្បីដល់ផ្ទៃទឹក។ អណ្តូងទឹក គឺជាប្រភពទឹកដែលអាចទុកចិត្តបាននៅរដូវប្រាំង បើប្រៀបធៀបជាមួយអណ្តូងជីក និងអណ្តូងទឹករាក់។ វាអាចធានាបាននូវប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋានក្នុងទំហំ 0.5-1.0 ហិកតា អាស្រ័យលើលំហូរទឹក។ ប្រសិនបើវាផ្គត់ផ្គង់ទៅស្រះកសិដ្ឋាន វាអាចស្រោចស្រពផ្ទៃដីធំជាងនេះ។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • ការបំពេញទឹកស្រះកសិដ្ឋានបន្ទាប់ពីប្រព័ន្ធធារាសាស្ត្រធានាថាមានទឹកពេញមួយឆ្នាំ។<br>• កសិករខ្លះក៏បានបូមទឹក និងស្រោចស្រពដំណាំរបស់ពួកគេដោយផ្ទាល់ផងដែរ។<br>• វាជាជម្រើសដ៏ល្អបំផុតសម្រាប់កសិករដែលមានដីតូច ហើយផ្តលអោយបានតែស្រះតូចៗប៉ុណ្ណោះ។ | • តម្លៃខួងដំបូងពី 800 ទៅ 3000 ដុល្លារ។<br>• នៅកន្លែងខ្លះវាពិបាកក្នុងការស្វែងរកអ្នកផ្តល់សេវាសម្រាប់ប្រតិបត្តិការខួងអណ្តូងធំៗ។<br>• ប្រភពថាមពលអគ្គិសនីដែលអាចទុកចិត្តបាន គឺត្រូវបានទាមទារដើម្បីដំណើរការម៉ាស៊ីនបូមទឹកក្រោមដី។<br>• ការបូមទឹកអណ្តូងដែលមិនបានត្រួតពិនិត្យអាចបន្ថយស្រទាប់ទឹកនៃអាងស្តុកទឹក។ ការសិក្សាផ្នែកជលសាស្ត្រនឹងត្រូវការចាំបាច់ដើម្បីប៉ាន់ប្រមាណអត្រាទាញយកអតិបរមាសម្រាប់អ្នកប្រើប្រាស់ទាំងអស់។ |

| ល.រ ២ | ទំនប់ស្នាក់ទឹក |
|---|---|
| **ប្រភេទ** | **ការអភិវឌ្ឍន៍ធនធានទឹក** |
| ការពិពណ៌នាខ្លី | រចនាសម្ព័ន្ធតូចមួយធ្វើពីថ្ម ឈើ ឬបេតុងដែលបន្ថយលំហូរពីប្រឡាយធម្មជាតិ ដូច្នេះបង្កើតអាងទឹកដែលមានកម្ពស់ខ្ពស់សម្រាប់សមត្ថភាពផ្ទុកបន្ថែម ឬកាត់បន្ថយល្បឿនលំហូរទឹកដើម្បីឱ្យវាអាចបូមចេញបាន។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • អាចបង្កើនកម្រិតទឹក និងបង្កើនសមត្ថភាពផ្ទុក; ធ្វើឱ្យម៉ាស៊ីនបូមទឹកងាយស្រួលគ្រប់គ្រង។<br>• ទាញយកប្រយោជន៍ពីប្រភពទឹកធម្មជាតិដោយមិនចាំបាច់ជីកស្រះ ជាពិសេសអូរដែលមានទឹកហូរនៅរដូវប្រាំង។<br>• ការបូមទឹកចេញពីទំនប់ស្នាក់មានតម្លៃតិចជាងការបូមចេញពីអណ្តូង។ មានតែម៉ាស៊ីនបូមតូចៗប៉ុណ្ណោះដែលត្រូវបានទាមទារ។ | • ការសាងសង់វាទាមទារជំនាញរចនាបច្ចេកទេស។ ប្រតិបត្តិករសេវាកម្មខ្នាតតូចមួយចំនួនខ្វះចំណេះដឹងក្នុងការគណនាកម្លាំងលំហូរទឹក និងភាពរឹងមាំសម្រាប់ការប្រើប្រាស់រយៈពេលវែង។<br>• កិច្ចព្រមព្រៀងស្តីពីបរិមាណទាញយកត្រូវតែធ្វើឡើងក្នុងចំណោមអ្នកប្រើប្រាស់ទាំងអស់ដែលមានសិទ្ធិប្រើការប្រឡាយ។<br>• អាចជះឥទ្ធិពលអវិជ្ជមានដល់ប្រព័ន្ធអេកូឡូស៊ី។ |

## បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| លរ ៣ | ស្រះកសិដ្ឋាន |
| --- | --- |
| **ប្រភេទ** | **ការអភិវឌ្ឍន៍ធនធានទឹក** |
| ការពិពណ៌នាខ្លី | ការប្រមូលទឹកពហុគោលបំណង និងកន្លែងផ្ទុកខ្នាតតូចដែលអាចផ្ទុកទឹកភ្លៀង ទឹកលើផ្ទៃដី ឬទឹកដែលបូមចេញពីអណ្តូង។ វាអាចផ្តល់ទឹកសម្រាប់ប្រើប្រាស់ក្នុងផ្ទះ ការចិញ្ចឹមសត្វ ដើមឈើហូបផ្លែ និងការស្រោចទឹកបន្លែ ហើយក្នុងករណីខ្លះ ការចិញ្ចឹមត្រី ឬការចិញ្ចឹមទា។ |



| គុណសម្បត្តិ | គុណវិបត្តិ |
| --- | --- |
| • រក្សាទឹក និងបង្កើតសមត្ថភាពផលិតកម្មពេញមួយឆ្នាំ ដោយរក្សាទុកទឹកសម្រាប់ប្រើប្រាស់នៅរដូវប្រាំង។<br>• បើកដំណើរការផលិតកម្មចម្រុះ ដូចជាការដាំដំណាំដែលមានតម្លៃខ្ពស់ ការចិញ្ចឹមទា និងត្រីជាដើម។<br>• ដើមឈើដែលមានខ្យល់បក់អាចជួយកាត់បន្ថយការហួត។ | • ហានិភ័យនៃការលេចធ្លាយ និងការបាត់បង់ទឹក ការបង្កើនតម្លៃបូម។<br>• ហានិភ័យនៃការបំពុល ដោយសារផ្ទៃទឹកបើកចំហ និងមិនមានការការពារ។<br>• ហានិភ័យនៃបង្កើតមូស ទោះបីជាវាអាចត្រូវបានគ្រប់គ្រងដោយការដាំប្រភេទដើមឈើមួយចំនួននៅជុំវិញបរិវេណ។<br>• ចាប់យកផ្ទៃដី។ |

| លរ ៤ | ស្រទាប់ស្រះ |
|---|---|
| **ប្រភេទ** | **ការស្តុក** |
| ការពិពណ៌នាខ្លី | គម្របការពារមិនអោយជ្រាបទឹកនៅបាត និងជ្រុងនៃស្រះ ដើម្បីជៀសវាងការបាត់បង់ទឹកដោយសារការជ្រាប។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| អាចពន្យាររយៈពេលទប់ទឹករបស់ស្រះ និងសន្សំសំចៃថ្លៃបូម។ | ថ្លៃដើម និងតម្រូវការប្តូរជាប្រចាំ។ |

## បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| ល.រ ៥ | ធុងស្តុកទឹក |
|---|---|
| **ប្រភេទ** | **ការអភិវឌ្ឍន៍ធនធានទឹក** |
| ការពិពណ៌នាខ្លី | ធុងស្តុកទឹកប្រើកម្លាំងទំនាញធម្មជាតិដើម្បីបង្កើតសម្ពាធទឹកនៅក្នុងប្រព័ន្ធធារាសាស្ត្រ។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • នៅពេលបំពេញរួច អាចអោយប្រព័ន្ធស្រោចស្រពដំណក់ដោយមិនបាច់បូម។<br>• ងាយស្រួលក្នុងការដំណើរការ។<br>• ងាយស្រួល SWS ព្រោះគ្រាន់តែត្រូវការបើកសន្ទះបិទបើកដើម្បីដំណើរការ។<br>• អាចភ្ជាប់ទៅសន្ទះបិតបើកឆ្លាតវៃសម្រាប់ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយស្វ័យប្រវត្តិតាមរយៈស្មាតហ្វូន ឬឧបករណ៍ចាប់សញ្ញាសំណើម។ | • ទាមទារការវិនិយោគដំបូងច្រើន។<br>• ដើម្បីទប់ទម្ងន់ទឹកក្នុងធុង ត្រូវមានការសាងសង់ពីដែក ឬបេតុងរឹងមាំ។<br>• សមត្ថភាពផ្ទុកទឹកតិច ដូច្នេះឆាប់អស់ បន្ទាប់មកត្រូវការការបំពេញឡើងវិញតាមរយៈការបូមម្តងទៀត។ |

| ល.រ ៦ | កន្លែងរក្សាទឹក |
|---|---|
| **ប្រភេទ** | **ការអភិវឌ្ឍន៍ធនធានទឹក** |
| ការពិពណ៌នាខ្លី | វាជាកន្លែងដែលទឹកក្រោមដីធ្វើចលនាដើម្បីរកច្រកចេញមកលើផ្ទៃដី។ តាមរយៈការថែរក្សាព្រៃជុំវិញប្រភពទឹក ឬសាងសង់របង ប្រភពទឹកអាចការពារពីការហូរច្រោះ ចូលរបស់សត្វពាហនៈ។ វាមានសារៈសំខាន់ដើម្បីការពារតំបន់ផ្តល់ទឹកដោយមានការព្រមព្រៀងថាព្រៃឈើត្រូវបានរក្សាទុក និងបង្កើនបរិមាណផ្តល់ទឹកជាមួយនឹងវិធានការជាក់លាក់ (បាច់ជ្រៀតចូល និងកន្លែងការពារ ស្រះពាក់កណ្តាល ឬ ស្រះបញ្ចូលទឹក)។ |
| **គុណសម្បត្តិ** | **គុណវិបត្តិ** |
| • ធានាទឹកសាបមានគុណភាពល្អ។<br>• វាមានសុវត្ថិភាពសម្រាប់មនុស្សក្នុងការផឹក និងមិនងាយស្ទួត។ | • នៅតំបន់ខ្លះប្រភពទឹកធម្មជាតិកំពុងធ្លាក់ចុះដោយសារការកាប់បំផ្លាញព្រៃឈើ ការអភិវឌ្ឍន៍ផ្លូវ និងការធ្វេសប្រហែស។ |

## បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| ល.រ ៧ | ម៉ាស៊ីនបូមទឹកសូឡា |
|---|---|
| **ប្រភេទ** | **បូមទឹក** |
| ការពិពណ៌នាខ្លី | សូឡាបូមទឹកភាគច្រើនជាម៉ាស៊ីនបូមទឹកដែលដំណើរការលើថាមពលដែលបង្កើតឡើងដោយបន្ទះសូឡា។ ការដំឡើងដែលមានគុណភាពខ្ពស់មានឧបករណ៍តាមដានពន្លឺព្រះអាទិត្យ និងឧបករណ៍បញ្ជា។ |






| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • នៅពេលដែលការវិនិយោគដំបូងក្នុងការដំឡើងឧបការណ៍សូឡាត្រូវបានធ្វើឡើង ការចំណាយលើការទាញយកទឹកក្រោមដីគឺជិតដល់សូន្យ។<br>• ម៉ាស៊ីនបូមទឹកដោយប្រើសូឡាដំណើរការល្អបំផុតនៅថ្ងៃដែលមានពន្លឺថ្ងៃ; ទាំងនេះក៏ជាពេលវេលានៃឆ្នាំផងដែរ ពេលដែលតម្រូវការទឹកស្រោចស្រពត្រូវការជាចាំបាច់បំផុត។<br>• ពួកគេកាត់បន្ថយថ្លៃដើមផលិតកម្ម និងបង្កើនឱកាសទីផ្សារជាពិសេសជាមួយនឹងតម្លៃប្រេងសាំងខ្ពស់។ | • តម្លៃដើមទុនខ្ពស់ ជាធម្មតាចន្លោះពី 1000-3000 ដុល្លារអាមេរិក<br>• ការបូមទឹកដោយឥតគិតថ្លៃអាចលើកទឹកចិត្តដល់ការប្រើប្រាស់ទឹកក្រោមដីដែលមិនអាចគ្រប់គ្រងបាន ដែលនាំឱ្យបាត់បង់ធនធានទឹកក្រោមដី។ ដូច្នេះ ការបូមទឹកដោយប្រើសូឡាគួរតែត្រូវបានបំពេញបន្ថែមដោយអភិបាលកិច្ចទឹកក្រោមដីក្នុងតំបន់។<br>• បន្ទាប់ពី 10-15 ឆ្នាំបន្ទះសូឡាត្រូវការជំនួស។<br>• បន្ទះសូឡាដែលមានតំលៃថោកមានអាយុកាលខ្លីជាង ហើយត្រូវបានខូចជាញឹកញាប់បង្កអោយមានភាពមិនទុកចិត្តរបស់កសិករចំពោះម៉ាស៊ីនបូមទឹកប្រើសូឡា។ |

| លរ ៨ | ម៉ាស៊ីនបូមទឹកប្រើសាំង |
|---|---|
| ប្រភេទ | ការទាញយកទឹក |
| ការពិពណ៌នាខ្លី | ម៉ាស៊ីនបូមទឹកដោយប្រើសាំង |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • តម្លៃដើមទុនដំបូងទាប (ឧ. 150 ដុល្លារ)។<br>• វាជាម៉ាស៊ីនបូមទឹកមានសមត្ថភាពទាប និងទម្ងន់ស្រាល ងាយស្រួលប្រើ និងផ្លាស់ទីពីដីមួយទៅដីមួយទៀត។<br>• សមស្របសម្រាប់ដីតូចៗ។<br>• សមស្របសម្រាប់ប្រភពទឹកដែលមានជម្រៅ 10 ម៉ែត្រ ឬតិចជាងនេះ។<br>• អាចត្រូវបានជួសជុលដោយមេកានិចភាគច្រើន។ | • ប្រើប្រាស់ប្រេងសាំងយ៉ាងច្រើនសន្ធឹកសន្ធាប់។<br>• តម្លៃប្រតិបត្តិការគឺខ្ពស់ជាងម៉ាស៊ីនបូមម៉ាស៊ូត។<br>• សម្ពាធទឹក គឺប្រហែល 1 bar ដែលដំណើរការល្អជាមួយខ្សែទឹក ប៉ុន្តែទាបពេកក្នុងការបូមទឹកក្នុងបរិមាណច្រើន។ |

# បញ្ជីនៃ SWS និងបច្ចេកវិទ្យាអាកាសធាតុឆ្លាតវៃ

| ល.រ ៩ | ម៉ាស៊ីនបូមទឹកម៉ាស៊ូត |
| --- | --- |
| **ប្រភេទ** | **ការទាញយកទឹក** |
| ការពិពណ៌នាខ្លី | ម៉ាស៊ីនម៉ាស៊ូតជាធម្មតាមានកម្លាំងចន្លោះពី 10-15 HP ដែលជំរុញម៉ាស៊ីនបូម សម្រាប់បូមទឹកលើផ្ទៃដី (រហូតដល់ 60 $m^3$/hour)។ ម៉ាស៊ីនម៉ាស៊ូតក៏អាចផ្តល់ថាមពលដល់ម៉ូទ័រដែលបង្កើតចរន្តអគ្គិសនី និងអាចផ្តល់ថាមពលដល់ម៉ាស៊ីនបូមទឹកដែលប្រើក្រោមទឹកបានផងដែរ។ |





| គុណសម្បត្តិ | គុណវិបត្តិ |
| --- | --- |
| • តម្លៃប្រតិបត្តិការ គឺទាបជាងម៉ាស៊ីនបូមសាំង។<br>• សមត្ថភាពបូមទឹកធំ និងលំហូរទឹក គឺសមរម្យសម្រាប់ប្រព័ន្ធធារាសាស្ត្រនៅក្នុងកសិដ្ឋានធំមួយ។<br>• សម្ពាធទឹកខ្ពស់សមរម្យសម្រាប់ការបាញ់ទឹក។ | • ធ្ងន់ និងពិបាកផ្លាស់ទីពីដីមួយទៅដីមួយទៀត។<br>• ទាមទារការថែទាំញឹកញាប់ និងមានតម្លៃប្រតិបត្តិការខ្ពស់ (ប្រេងឥន្ធនៈ)។<br>• លុះត្រាតែវាបំពាក់ដោយថ្ម វាទាមទារការចាប់ផ្តើមទាត់ដោយដៃ។ |

| ល.រ ១០ | កៅស៊ូគ្របរង |
|---|---|
| **ប្រភេទ** | **សន្សំទឹក / រក្សាសំណើមដី** |
| ការពិពណ៌នាខ្លី | កៅស៊ូគ្របរងកាត់បន្ថយការហួតដី ដូច្នេះបរិមាណស្រោចស្រប ត្រូវការ។ វាមានឥទ្ធិពលលើសីតុណ្ហភាពដី ដូច្នេះបង្កើនល្បឿន ដំណុះគ្រាប់ពូជ។ ផ្លាស្ទិកពណ៌ខ្មៅអាចប្រើដើម្បីបង្កើនសីតុណ្ហភាព ដី ខណៈដែលផ្លាស្ទិចពណ៌សឆ្លុះបញ្ចាំងធ្វើឱ្យដីត្រជាក់។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • កាត់បន្ថយការហួតដី និងគ្រប់គ្រងសីតុណ្ហភាពដី។<br>• បន្ថយស្មៅ។ | • កៅស៊ូគ្របរងងាយខូច និងបំពុលដីជាមួយនឹងសំណល់ផ្លាស្ទិច ដែលមានរយៈពេលយូរ។ នៅក្នុងប្រទេសមួយចំនួន ថង់ប្លាស្ទិក ដែលបោះចោលត្រូវបានប្រមូលសម្រាប់ប្រើប្រាស់ឡើងវិញ ដើម្បីកាត់បន្ថយការបំពុល។ កៅស៊ូអាចរំលាយបានត្រូវបាន បង្កើតឡើង ប៉ុន្តែវានៅតែមានតម្លៃថ្លៃ និងមិនប្រើប្រាស់ បានយូរ។ |

# បញ្ជីនៃ SWS និងបច្ចេកវិទ្យាអាកាសធាតុឆ្លាតវៃ

| ល.រ ១១ | ចំបើង / គម្របដីសរីរាង្គ |
|---|---|
| **ប្រភេទ** | **ការសន្សំទឹក / ការរក្សាសំណើមដី** |
| ការពិពណ៌នាខ្លី | ការប្រើប្រាស់ចំបើងជាគម្របដើម្បីជួយកាត់បន្ថយការហួតដី និងគ្រប់គ្រងសីតុណ្ហភាពដី ទោះបីជាវាមានប្រសិទ្ធភាពតិចជាងការប្រើបាស្ទិកក៏ដោយ។ អនុផលសរីរាង្គផ្សេងទៀត ដូចជាស្លឹកចេក ក៏អាចត្រូវបានគេប្រើប្រាស់ផងដែរ។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • កាត់បន្ថយការហួតដី និងគ្រប់គ្រងសីតុណ្ហភាពដី។<br>• ការពារដីខាងលើពីខ្យល់ និងភ្លៀង។<br>• បង្កើនសារធាតុសរីរាង្គដី។<br>• អាចបំបែកបាន និងមិនប៉ះពាល់ដល់បរិស្ថាន។ | • អាចនាំមកនូវជំងឺមួយចំនួនដែលភ្ជាប់ទៅនឹងផ្សិត ឬភ្នាក់ងារបង្កជំងឺផ្សេងទៀត។<br>• មានប្រសិទ្ធភាពតិចក្នុងការគ្រប់គ្រងស្មៅ។ |

| ល.រ ១២ | ដំណាំគម្រប |
|---|---|
| **ប្រភេទ** | **សន្សំទឹក / រក្សាសំណើមដី** |
| ការពិពណ៌នាខ្លី | ដំណាំអចិន្ត្រៃយ៍ ឬប្រចាំឆ្នាំដែលបង្កើតជាគម្របបន្លែបៃតងនៅលើដី និងសាបព្រោះ ជាពិសេសដើម្បីបង្កើនជីជាតិរបស់ដីដោយមិនផ្តល់ផលផលដែលអាចប្រមូលផលបាន។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • ចំណាយតិច<br>• ការពារដី និងបង្កើនសារធាតុសរីរាង្គ<br>• អាសូត - ជួសជុលប្រសិនបើមកពីគ្រួសារ legume ។ | • ក្នុងករណីអន្តរដំណាំ កសិករត្រូវយល់ដឹងពីការគ្រប់គ្រងដំណាំដើម្បីកាត់បន្ថយដំណាំប្រជែងគ្នា។<br>• តម្រូវឱ្យមានកម្លាំងពលកម្មដើម្បីសាបព្រោះ និងគ្រប់គ្រងខណៈដែលមិនមានផលសម្រាប់ប្រមូលផល និងលក់។ |

## បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| ល.រ ១៣ | កំពែងតូចៗ |
|---|---|
| **ប្រភេទ** | **សន្សំទឹក / រក្សាសំណើមដី** |
| ការពិពណ៌នាខ្លី | កំពែងតូចមួយនៅជុំវិញគល់ឈើជួយរក្សាទឹកស្រោចស្រព។ វាត្រូវបានធ្វើជាញឹកញាប់ដើម្បីកាត់បន្ថយលំហូរទឹក និងដើម្បីរក្សាទុកទឹកភ្លៀងនៅក្នុងដីសម្រាប់ដំណាំស្រូបយក។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • មានប្រសិទ្ធភាព និងចំណាយតិច<br>• អាចត្រូវបានផ្សំជាមួយទុយោដំណក់ទឹក។<br>• សំណើមដីកាន់តែប្រសើរ កាត់បន្ថយការធ្លាក់ផ្កា និងបង្កើនការលូតលាស់ផ្លែ។ | • ការចំណាយលើការបង្កើត។<br>• ហានិភ័យនៃការលិចទឹកនៅក្នុងដីដែលមានប្រព័ន្ធបង្ហូរទឹកមិនល្អ។ |

| ល.រ ១៤ | ការដាំជាជួរ |
|---|---|
| **ប្រភេទ** | **សន្សំទឹក / រក្សាសំណើម** |
| ការពិពណ៌នាខ្លី | លើកជួរខ្ពស់ដើម្បីធ្វើរងសម្រាប់ដាំដុះ |





| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • ខ្យល់ល្អសម្រាប់ឫស។<br>• ងាយស្រួលប្រមូលផលផល<br>• ជៀសវាងទឹកដក់ | ពឹងផ្អែកលើកម្លាំងពលកម្ម ប្រសិនបើមិនមានយន្តការ។ |

## បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| ល.រ ១៥ | កម្រិតដីច្បាស់លាស់ |
|---|---|
| **ប្រភេទ** | **សន្សំទឹក / រក្សាសំណើមដី** |
| ការពិពណ៌នាខ្លី | បច្ចេកវិជ្ជាឡាស៊ែរត្រូវបានប្រើប្រាស់ដើម្បីធានាថាមិនមានការប្រែប្រួលនៃកម្ពស់ដី ដូច្នេះទឹកអាចចែកចាយបានស្មើៗគ្នានៅទូទាំងវាល។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • ជៀសវាងការចែកចាយទឹកមិនស្មើរក្នុងវាល ពោល គឺនៅពេលដែលតំបន់ខ្លះទទួលបានទឹកច្រើនពេក និងកន្លែងខ្លះទៀតតិចពេក។ | • ត្រូវការបច្ចេកវិជ្ជាឡាស៊ែរច្បាស់លាស់ និងសេវាកម្មត្រាក់ទ័រ។ |

| លេ.រ ១៦ | ជីកំប៉ុសដី និងជីវឧស្ម័ន |
|---|---|
| **ប្រភេទ** | **សន្សំទឹក / រក្សាសំណើមដី** |
| ការពិពណ៌នាខ្លី | សមត្ថភាពរក្សាទឹកក្នុងដីត្រូវបានធ្វើឱ្យប្រសើរឡើងដោយការបន្ថែមសារធាតុសរីរាង្គ។ មានសារធាតុបន្ថែមដីដែលមិនមែនជាជីគីមីជាច្រើនប្រភេទ៖ ជីកំប៉ុស ជីជីវឧស្មន កំបោរ។ល។ ពួកវាអាចដាក់នៅគ្រប់ទីកន្លែងនៅលើវាលស្រែ ឬកន្លែងជាក់លាក់ ដូចជានៅក្នុងអាងខ្នាតតូចជាដើម។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • ធ្វើអោយប្រសើរឡើងនូវសំណើមដី និងសមត្ថភាពរក្សាទឹករបស់ដី។<br>• ធ្វើអោយប្រសើរឡើងនូវរចនាសម្ព័ន្ធដី ជីវិត និងជីជាតិ ហើយបញ្ចេញសារធាតុចិញ្ចឹមបន្តិចម្តងៗ។<br>• កាត់បន្ថយតម្រូវការសម្រាប់ស្រោចស្រព។ | • ដីធំត្រូវការជីកំប៉ុសច្រើន ដែលប្រហែលជាមិនអាចរកបានក្នុងបរិមាណច្រើនទេ។<br>• ពឹងផ្អែកលើកម្លាំងពលកម្មច្រើន។ |

## បញ្ជីនៃ SWS និងបច្ចេកវិទ្យាអាកាសធាតុឆ្លាតវៃ

| លៈរ ១៧ | ប្រព័ន្ធដំណក់ទឹក |
|---|---|
| **ប្រភេទ** | **សន្សំទឹក** |
| ការពិពណ៌នាខ្លី | ដោយការបញ្ចេញទឹកក្នុងបរិមាណតិចតួចនៅជិតឫសរបស់រុក្ខជាតិ។ ទឹកត្រូវបានចែកចាយយ៉ាងមានប្រសិទ្ធភាព។ ប្រព័ន្ធដំណក់ទឹកតាមជួរ គឺអាចរកបាន។ |





| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • អាចផ្តល់ជីទឹកលាយជាមួយទឹកស្រោចស្រព - ការរួមបញ្ចូលគ្នាដែលគេស្គាល់ថាជា «ដំណក់»។<br>• ចំណេញពេលវេលា និងបង្កើនផលិតភាព។ | • ចំណាយថ្លៃបន្តិច បើទោះជាមានជម្រើសច្រើនជាមួយនឹងតម្លៃខុសៗគ្នាក៏ដោយ។<br>• ហានិភ័យនៃការស្ទះបំពង់<br>• ត្រូវការផ្លាសប្តូរជាប្រចាំ និងបណ្តាលឱ្យមានការបំពុលប្លាស្ទិក<br>• ហានិភ័យនៃការចាក់ឫសរាក់នៃដើមឈើហូបផ្លែ ដែលធ្វើឱ្យពួកវាងាយរងគ្រោះរាំងស្ងួត និងខ្យល់ |

| លេ.រ ១៨ | ក្បាលបាញ់ទឹកខ្នាតតូច |
|---|---|
| **ប្រភេទ** | **សន្សំទឹក** |
| ការពិពណ៌នាខ្លី | ឧបករណ៍បាញ់ទឹកតូចមួយ បាចទឹកឱ្យស្មើគ្នាលើផ្ទៃដំណាំ។ សមស្របសម្រាប់បន្លែមើម ។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • បាញ់ទឹកឱ្យស្មើគ្នាលើវាល<br>• ស័ក្តិសមប្រសិនបើស្រោចមើមផ្តល់ហានិភ័យនៃការរលួយនៃបន្លែ ឧ. ជាមួយនឹងការ៉ុតនិងខ្ទឹមបារាំង<br>• អាចដំណើរការដោយស្វ័យប្រវត្តិ<br>• វាជួយកាត់បន្ថយការប្រើប្រាស់ទឹក ជី និងតម្រូវការកម្លាំងពលកម្ម | • តម្លៃវិនិយោគខ្ពស់<br>• ការប្រើប្រាស់ទឹកខ្ពស់ ដោយសារតែសាច និងការហួត |

# បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| ល.រ ១៩ | បំពង់បាញ់ទឹកភ្លៀង |
|---|---|
| **ប្រភេទ** | **សន្សំទឹក** |
| ការពិពណ៌នាខ្លី | ទុយោស្រោចស្រពដែលមានរន្ធតូចៗជាច្រើន ដែលត្រូវបានគេស្គាល់ថាជាទុយោបាញ់ទឹកភ្លៀង ដើម្បីបង្កើតជាដំណក់ទឹកតូចៗដែលបាញ់ទៅលើដំណាំ/រង។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • សន្សំកំលាំងពលកម្ម ពេលវេលា និងថាមពល<br>• ងាយស្រួលតំឡើង<br>• ត្រូវប្រាកដថាដំណក់ទឹកតូចៗត្រូវបានបាញ់ស្មើៗគ្នាលើរងដំណាំ។<br>• ការវិនិយោគដែលមានតម្លៃទាបធៀបនឹងបណ្ដាញដំណក់។<br>• ល្អសម្រាប់បន្លែស្លឹក។<br>• ធ្វើការនៅសម្ពាធទឹកទាប។<br>• ស័ក្តិសមសម្រាប់ដំណាំដែលមានគម្លាតជិត | • មានរយៈពេលត្រឹមតែមួយ ឬពីរវដ្តដំណាំប៉ុណ្ណោះ<br>• ស្មៅ គឺជាកង្វល់មួយ<br>• បណ្ដាលឱ្យមានកាកសំណល់ប្លាស្ទិក។<br>• ការបាត់បង់ការហួតបរិយាកាសខ្ពស់ |

| លេខ ២០ | ផ្ទះសំណាញ់ |
|---|---|
| **ប្រភេទ** | **សន្ទស្សន៍** |
| ការពិពណ៌នាខ្លី | ផ្ទះសំណាញ់ដែលមានតម្លៃទាប បង្កើតបរិយាកាសដែលអាចគ្រប់គ្រងបានសម្រាប់ដំណាំដាំដុះ គ្រប់គ្រងសីតុណ្ហភាព សំណើម និងហូត។ |





| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • គ្រប់គ្រងបរិស្ថានលូតលាស់ និងការពារដំណាំពីភ្លៀងធ្លាក់ខ្លាំង។<br>• មានច្រើនជម្រើស ចាប់ពីតម្លៃទាប រហូតដល់តម្លៃថ្លៃ។<br>• អាចត្រូវបានភ្ជាប់ជាមួយវិធានការផ្សេងទៀត ដូចជាប្រព័ន្ធធារាសាស្ត្រស្រក់ ក្បាលបាញ់ទឹកតូចៗ ជីកំប៉ុស/ជីជីវ និងកៅស៊ូគ្របរង។ | • ការចំណាយលើការវិនិយោគច្រើន។<br>• មិនស័ក្តិសមសម្រាប់ដំណាំកសិកម្មខ្នាតធំដូចជាធញ្ញជាតិ។<br>• កសិករត្រូវគ្រប់គ្រងការឡើងកំដៅ និងសំណើមនៅខាងក្នុងសំណាញ់។ |

# បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| ល.រ ២១ | ទុយោទឹក PVE |
|---|---|
| ប្រភេទ | សន្សំទឹក |
| ការពិពណ៌នាខ្លី | ទុយោទឹក PVE បញ្ជូនទឹកពីប្រភពទៅតំបន់ឆ្ងាយៗក្នុងកសិដ្ឋាន។ |





| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • មិនមានការបាត់បង់ទឹក បើប្រៀបធៀបទៅនឹងប្រឡាយ។<br>• អាចឆ្លងកាត់ទីវាលគ្មានកម្រិត។<br>• ធន់នឹងទៅនឹងពន្លឺព្រះអាទិត្យជាងទុយោ PVC ដែលមិនសូវងាយនឹងបែក ឬលេចធ្លាយ។ | • អាចមានតម្លៃថ្លៃ<br>• ទុយោ PVE ត្រូវបានណែនាំព្រោះវាប្រើប្រាស់បានយូរជាងទុយោ PVC ប៉ុន្តែវាមានតម្លៃថ្លៃជាង។ |

| ល.រ ២២ | ទុយោបត់ |
|---|---|
| **ប្រភេទ** | **សន្សំទឹក** |
| ការពិពណ៌នាខ្លី | ទុយោប៉ូលីអេទីឡែនបញ្ជូនទឹកពីស្នប់តាមរយៈទុយោដែលបំពេញនៅពេលដែលសម្ពាធទឹកត្រូវបានបញ្ចូល។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • ងាយស្រួលប្រើ និងដឹកជញ្ជូនទៅកាន់ផ្នែកផ្សេងៗនៅទីវាល។ | • អាស្រ័យលើគុណភាព វាអាចត្រូវការជំនួសរៀងរាល់ 1-3 ឆ្នាំម្ដង។ |

## បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| ល.រ ២៣ | ឧបករណ៍ចាប់សញ្ញាសំណើម |
|---|---|
| **ប្រភេទ** | **សន្សំទឹក** |
| ការពិពណ៌នាខ្លី | ឧបករណ៍ចាប់សញ្ញាសំណើមត្រូវបានដាក់នៅក្នុងដី និងវាស់សំណើមដីតាមបណ្តោយរងដំណាំ។ វាបញ្ជូនសញ្ញាទៅកុំព្យូទ័រ ឬទូរស័ព្ទ ហើយចង្អុលបង្ហាញថានៅពេលណាដែលការស្រោចស្រពត្រូវធ្វើ។ ប្រហែល 4 លើមួយហិកតាត្រូវបានប្រើប្រាស់។ |





| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • អាចត្រូវបានដំឡើងជាមួយប្រព័ន្ធធារាសាស្ត្រស្វ័យប្រវត្តិ។ | • ត្រូវការការក្រិតតាមខ្នាតត្រឹមត្រូវ ដើម្បីធានាបាននូវសំណើមត្រឹមត្រូវសម្រាប់ដំណាំនីមួយៗ។ |

| ល.រ ២៤ | អាងស្តុកទឹករួម |
|---|---|
| **ប្រភេទ** | **ការគ្រប់គ្រងធនធានទឹករួម** |
| ការពិពណ៌នាខ្លី | អាងស្តុកទឹកដ៏ធំដែលជីកនៅលើដីសហគមន៍ ដែលផ្ទុកទឹកភ្លៀង និងទឹកហូរសម្រាប់សហគមន៍ប្រើប្រាស់។ ជាធម្មតាមានជម្រៅពី 4-6 ម៉ែត្រ និងវាស់ពី 50x100 ម៉ែត្រទៅជាច្រើនហិកតា។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • ស្រះស្តុកទឹកធំប្រើសម្រាប់ស្រោចស្រព និងចិញ្ចឹមសត្វនៅរដូវប្រាំង។<br>• គាំទ្រការជ្រៀតចូលទឹកទៅក្នុងទឹកក្រោមដី ដែលអនុញ្ញាតឱ្យទឹកបំពេញបន្ថែម។ | • ការថែទាំត្រូវបានទាមទារដើម្បីការពារអាងស្តុកទឹកពីការបំពេញដោយដីសំណឹក។<br>• ត្រូវការកិច្ចព្រមព្រៀងចែករំលែកច្បាស់លាស់ ដូច្នេះបរិក្ខានេះអាចផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ទាំងមូល។<br>• ត្រូវការកិច្ចព្រមព្រៀងសម្រាប់ការថែទាំ និងការទូទាត់របស់អ្នកប្រើប្រាស់។ |

## បញ្ជីនៃ SWS និងបច្ចេកវិជ្ជាអាកាសធាតុឆ្លាតវៃ

| ល.រ ២៥ | ប្រឡាយចែកចាយជាមួយច្រកទ្វារទឹក។ |
|---|---|
| ប្រភេទ | ការគ្រប់គ្រងធនធានទឹករួម |
| ការពិពណ៌នាខ្លី | បញ្ជូនទឹកពីប្រភពធម្មជាតិទៅអាងស្តុកទឹក។ |



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| • អាចបញ្ជូនបរិមាណទឹកច្រើន | • ថ្លៃដើមខ្ពស់<br>• ការថែទាំតម្រូវអោយធ្វើ<br>• កិច្ចព្រមព្រៀងច្បាស់លាស់សម្រាប់ការប្រើប្រាស់ទឹក និងការទូទាត់ចាំបាច់ត្រូវមាន |

# ឧបសម្ព័ន្ធ៣

## ប្រធានបទសម្រាប់ការវាយតម្លៃបឋម

| រយៈពេល | សកម្មភាព | គោលបំណង/លទ្ធផល | នរណា |
|---|---|---|---|
| | ចុះឈ្មោះ | បញ្ជីឈ្មោះអ្នកចូលរួម | ក្រុមគម្រោង |
| 10 នាទី | មតិស្វាគមន៍ និងសុន្ទរកថាបើក | - | អភិបាលស្រុក ឬតំណាង |
| 20 នាទី | បទបង្ហាញអំពីការអភិវឌ្ឍន៍កសិកម្មក្នុងខេត្ត | បទបង្ហាញខ្លីៗស្តីពីការអភិវឌ្ឍន៍កសិកម្ម | ប្រធាន ឬតំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| 5 នាទី | ថតរូបជាក្រុម | - | អ្នកចូលរួមទាំងអស់ |
| 20 នាទី | បទបង្ហាញអំពីគម្រោង និងការរកឃើញនៃការវាយតម្លៃ | ការរកឃើញបច្ចុប្បន្ននៃការវាយតម្លៃរហ័ស | ទីប្រឹក្សាបច្ចេកទេស |
| 30 នាទី | វគ្គបំផុសគំនិតលើបញ្ហាសំខាន់បំផុត | បញ្ជាក់បញ្ហាអាកាសធាតុសំខាន់ៗដោយសរសេរវានៅលើកាត | អ្នកសម្របសម្រួល |
| 40 នាទី | ការពិភាក្សាជាក្រុមតូច (៥ក្រុម)<br>• វិស័យសាធារណៈ<br>• ពាណិជ្ជករ/អ្នកផ្គត់ផ្គង់បញ្ចូល/MFIs/អ្នកផ្តល់សេវា<br>• ដៃគូអភិវឌ្ឍន៍<br>• អ្នកផលិត/កសិករ | ប្រើកាតតូចៗជាមួយនឹងបញ្ហាប្រឈមដែលបានសរសេរចុះ។ អនុញ្ញាតឱ្យអ្នកចូលរួមដាក់ចំណាត់ថ្នាក់ពួកគេតាមលំដាប់អាទិភាព ហើយអនុញ្ញាតឱ្យពួកគេកំណត់ដំណោះស្រាយដែលអាចធ្វើទៅបាន។ | - |
| 15 នាទី | សំរាកអាហារសម្រន់ | - | អ្នកចូលរួមទាំងអស់ |
| 25 នាទី | បទបង្ហាញតាមក្រុម | ដើម្បីចែករំលែកលទ្ធផលនៃកិច្ចពិភាក្សាជាក្រុមតូច | តំណាងក្រុមនីមួយៗ |
| 15 នាទី | កិច្ចពិភាក្សាជាមួយសំណួរ និងចម្លើយ | ទិដ្ឋភាពទូទៅនៃការរកឃើញសំខាន់ៗ | អ្នកសម្របសម្រួល និងទីប្រឹក្សាបច្ចេកទេស |
| 20 នាទី | បទបង្ហាញពីម្ចាស់ហាងលក់បច្ចេកវិជ្ជា SWS | បច្ចេកវិជ្ជាផ្សេងៗគ្នាបានពន្យល់យ៉ាងខ្លី និងផ្សព្វផ្សាយ | ម្ចាស់ហាង |
| 30 នាទី | វគ្គផ្គូផ្គងរវាងក្រុមកសិករ និងអ្នកផ្តល់សេវា | ការពិភាក្សាលើផលប្រយោជន៍ កំណត់តម្រូវការសក្តានុពល | អ្នកចូលរួមទាំងអស់ |
| 10 នាទី | សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់ | - | អ្នកសម្របសម្រួល |
| 10 នាទី | សុន្ទរកថាបិទ | - | ប្រធាន ឬតំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | អាហារថ្ងៃត្រង់ | - | អ្នកចូលរួមទាំងអស់គ្នា |

# ឧបសម្ព័ន្ធ៤

## កម្រងសំណួរសម្រាប់ការវាយតម្លៃកសិដ្ឋាននីមួយៗ និងផែនការវិនិយោគ

| | | |
|---|---|---|
| ឈ្មោះ: | អាយុ: | ភេទ: |
| អាស័យដ្ឋាន: | | |
| ទំហំចម្ការ: | | |

1. ប្រតិទិនដំណាំ៖ (ការយល់ដឹងអំពីសកម្មភាពសំខាន់ៗ និងរយៈពេល)

2. តើហេតុអ្វីបានជាអ្នកចង់ដាំបន្លែពេញមួយឆ្នាំ?

3. តើមានបញ្ហាទឹកជ្រាបមែនទេ? តើអ្នកដោះស្រាយវាដោយរបៀបណា?

4. តើអ្នកមានបញ្ហាបញ្ហាស្ងួតក្នុងរដូវភ្លៀងដែរឬទេ?

5. តើអ្នកខ្វះខាតទឹកនៅក្នុងកសិដ្ឋានរបស់អ្នកជាធម្មតាចាប់ផ្តើមនៅពេលណា? តើអ្នកដោះស្រាយវាដោយរបៀបណា?

| អណ្តូង | ស្រះ |
|---|---|
| ទទួលបានអណ្តូង៖ បាទ/ចាស | ទទួលបានស្រះ៖ បាទ/ចាស |
| ប្រភេទអណ្តូង៖ | ប្រភេទស្រះ៖ (ទឹកចេញមកឬអត់?) |
| ជម្រៅ៖ | ទំហំ និងជម្រៅ៖ |
| ជម្រៅនៅរដូវប្រាំង៖ | ជម្រៅនៅរដូវប្រាំង៖ |
| តើអ្នកចង់ធ្វើអ្វីជាមួយវា (ឧ. ខួងឡើងវិញ)? | តើអ្នកចង់ធ្វើអ្វីជាមួយវា? |
| ការចំណាយសរុបប៉ាន់ស្មាន៖ | ការចំណាយសរុបប៉ាន់ស្មាន៖ |
| ចំនួនទឹកប្រាក់ដែលចង់វិនិយោគ៖ | ចំនួនទឹកប្រាក់ដែលចង់វិនិយោគ៖ |

# តម្រូវការទឹក

## បូម៖

1. ទទួលម៉ាស៊ីនបូម៖ បាទ/ចាស
2. ប្រភេទបូម (សាំង/ម៉ាស៊ូត/សូឡា/អគ្គិសនី)៖
3. សមត្ថភាពបូម (HP):
4. បញ្ហាណាមួយ?
5. តើអ្នកដោះស្រាយបញ្ហាទាំងនេះដោយរបៀបណា?

## ការគ្រប់គ្រងទឹក

**តើអ្នកប្រើវិធីណាដើម្បីស្រោចស្រពដំណាំរបស់អ្នក?**

a. ដំណក់ទឹក/បាញ់ទឹកភ្លៀង/បាញ់ទឹក/ទុយោរាបស្មើ
b. តើអ្នកថែទាំឧបករណ៍អ្វីខ្លះ?
c. តើអ្នករក្សាទុកឧបករណ៍ដោយរបៀបណាបន្ទាប់ពីប្រើប្រាស់?
d. តើពេលណាអ្នកស្រោចស្រពដំណាំរបស់អ្នក? ជាញឹកញាប់? តើអ្នកពិនិត្យមើលសំណើមដីមុនពេលស្រោចស្រពទេ?

**តើអ្នកបានដាក់អ្វីលើរងបន្លែរបស់អ្នកដើម្បីរក្សាសំណើមទេ?**

a. កៅស៊ូគ្របរង
b. ចំបើង
c. អ្វីផ្សេងទៀត (ពណ៌នា៖ ______________________)

**តើអ្នកមានផ្ទះសំណាញ់ទេ? បាទ/ចាស**

**ប្រភេទផ្ទះសំណាញ់ (ឧ. រូងប្លាស្ទិក)៖** ______________________

**ទំហំផ្ទះសំណាញ់ (គិតជាម៉ែត្រការ៉េ)៖** ______________________

**តើអ្នកចាប់អារម្មណ៍លើផ្ទះសំណាញ់ថ្មីដែរ ឬទេ? បាទ/ចាស**

**ប្រភេទ?** ______________________ **ទំហំ?** ______________________

**តើដំណាំដែលត្រូវដាំដុះ និងចំនួនវដ្ត?** ______________________

**តើអ្នកមានទីផ្សារសុវត្ថិភាពដែរ ឬទេ? បាទ/ចាស**



**SNV កម្ពុជា**
#១២០ ផ្លូវ៥១(កែង២២៨) ជាន់ទី៥ ភូមិទី៤ សង្កាត់ចតុមុខ ខណ្ឌដូនពេញ
ក្រុងភ្នំពេញ កម្ពុជា

ទូរស័ព្ទ៖ +៨៥៥ ១៧ ៦៤៤ ៨៨២
អ៊ីម៉ែល៖ cambodia@snv.org
គេហទំព័រ៖ www.snv.org/country/cambodia
ហ្វេសប៊ុក៖ @SNVCambodia